ANN Tay Kim

# នមស្ការព្រះរតនត្រ័យ
# ពិធីបុណ្យពុទ្ធសាសនា និង
# បុណ្យប្រពៃណីខ្មែរ

Editions  Vatt Bodhivansa
101, Boulevard de la République
77420 Champs sur Marne (France)
Tel : 01 60 06 44 98

e-mail : anntaykim@yahoo.fr
site : www.btkhmer.com

*ខ្ញុំសូមឧទ្ទិស កុសលផលបុណ្យ ដែលបានកើតឡើងអំពីធម្មទាននេះ ជូនចំពោះលោកអ្នកដ៏មានគុណទាំងឡាយ ដែលធ្វើមរណកាល ទៅហើយ មាន ៖*

*-ភិក្ខុ* **សៅ ម៊ុល** *ចៅអធិការ វត្តមង្គលសត្ថារ៉ែន ភូមិព្រៃកតាគង់ ឃុំព្រៃកតាសេក ស្រុកមុខកំពូល ខេត្តកណ្តាល*

*-ឧបាសក* ***ខូវ សេងអាន*** *(ឃុំបាក់ខែង)*

*-ឧបាសិកា* ***សាន់ ផែល*** *(ឃុំបាក់ខែង)*

*-លោក* **អាន ស៊ុនហេង** *(ភូមិព្រៃកតាគង់)*

*-អ្នកស្រី* **អ៊ា គិមអេង** *(ភូមិព្រៃកតាគង់)*

*ដែលត្រូវជា គ្រូឧបជ្ឈាយ៍ ជីតា ជីដូន ឪពុក ម្តាយ ជាដើម ។*

# អារម្ភកថា

សៀវភៅនេះខ្ញុំរៀបរៀងឡើងដើម្បីជាជំនួយដល់យុវជនយុវតីខ្មែរ ដែលមានបំណង
ចង់រៀន ធម៌សូត្រថ្វាយបង្គំព្រះ(ធម៌នមស្សការ) និងធម៌ ខ្លះទៀត ទាក់ទងក្នុងពិធី
បុណ្យពុទ្ធសាសនា បុណ្យជាតិ ឬ បុណ្យប្រពៃណី ។
ម្យ៉ាងទៀតនៅពេលពិធីបុណ្យម្តងៗកម្មវិធីជាលំដាប់លំដោយ ហាក់ដូចជាវែងអន្លាយ
ធ្វើឲ្យអ្នក ដែលមិនបានយល់មានការធុញទ្រាន់។ ហេតុនេះហើយ បានជានៅក្នុងសៀវ
ភៅនេះ ខ្ញុំសូមលើកយកមករៀបរាប់ជាលំដាប់លំដោយនូវកម្មវិធីនៃបុណ្យនីមួយៗទាំង
បុណ្យពុទ្ធសាសនា និងបុណ្យប្រពៃណី។នៅផ្នែកខាងចុងនៃសៀវភៅនេះ ខ្ញុំបានដកស្រង់
យកអត្ថបទខ្លះដែលជាប់ ទាក់ទងនឹងបុណ្យ របស់ខ្មែរយើង សរសេរ ដោយលោក
រស់ វ៉ាន់ថា អតីត វិស្វករ និងសាស្ត្រាចារ្យនៅវិទ្យាល័យស៊ីសុវត្ថិក្រុងភ្នំពេញ ស្តីពីប្រតិទិន
ថ្ងៃបុណ្យនានា ចាប់ ពីឆ្នាំ ២០១៥ ដល់ ឆ្នាំ ២០២៤។
ខ្ញុំសូម អរព្រះគុណ អរគុណ ព្រះអង្គគ្រូ ងិន ភេន និងព្រះអង្គចៅអធិការ ពេជ្រសាម៉ុន
ដែលបានជួយកែសម្រួលន័យនិងសេចក្តីផ្សេងៗ និងព្រះសង្ឃ ព្រមទាំងពុទ្ធបរិស័ទ
វត្តពោធិវង្ស ដែលបានជួយជ្រោមជ្រែង ធ្វើឲ្យសៀវភៅនេះកើតឡើង ដើម្បី ចែក ជូន
ជា ធម្មទាន។

ខ្ញុំសង្ឃឹមថាសៀវភៅនេះ អាចផ្តល់ប្រយោជន៍ខ្លះ ជូនលោកអ្នកជាមិនខាន ។

សង់សៀម៉ាណា ថ្ងៃទី ១៥ ឧសភា ឆ្នាំ ២០១៤ ។

មាតិកា ------------------------------------- ទំព័រ


១- លំនាំដើម.........................................................................៥

២- ភាសាបាលីសរសេរជាអក្សរខ្មែរ និងអក្សរឡាតាំង.....................៧

- របៀបអានភាសាបាលី...........................................................៨

៣- នមស្សការ ព្រះរតនត្រ័យ ...........................................១០

ថ្វាយបង្គំសូមសេចក្តីសុខ (ឥច្ចេ) ..................................................... ១៤

៤- សីល ៥ (និច្ចសីល)...................................................................១៥

៥- សីលឧបោសថ (សីល ៨)..............................................................១៦

៦- វេរភត្ត.....................................................................................១៧

៧- ធម៌ផ្សាយចំណែកបុណ្យ

បត្តិទានគាថា(យំកិញ្ចិ)....................................................................១៨

តេជះខ្ញុំសាង................................................................................ ១៩

៨- ពិធីបុណ្យផ្សេងៗ តាមទំនៀមទម្លាប់ និង បុណ្យពុទ្ធសាសនា

<u>៨-១ បុណ្យប្រពៃណី</u> ............................................... ២០

១-ចំរើនបរិត្ត....................................................................................២០

២-បុណ្យទក្ខិណានុប្បទាន.....................................................................២១

៣-បុណ្យផ្កា.........................................................................................២២

៤-បុណ្យបច្ច័យ៤..................................................................................២៣

៥-បុណ្យភ្ជុំ..........................................................................................២៥

៦-បុណ្យចូលឆ្នាំខ្មែរ........................................................................... ២៦

៧-ពិធីរៀបមង្គលការ...........................................................................២៧

៨-បុណ្យជូនកុសល ដល់មនុស្សឈឺ ឬមនុស្សស្លាប់.......................៣៦

<u>៨-២ បុណ្យពុទ្ធសាសនា</u> ...........................................................៤០

១-បុណ្យមាឃបូជា.....................................................៤០
២-បុណ្យពិសាខបូជា..................................................៤១
៣-បុណ្យចូលវស្សា....................................................៤២
៤-បុណ្យចេញវស្សា...................................................៤៣
៥-បុណ្យកឋិន..........................................................៤៤
៩- ឯកសារផ្សេងៗ ជាប់នឹងទំនៀម ទម្លាប់ខ្មែរ..............................៤៦
៩-១ មហាសង្ក្រាន្ត..........................................................៤៦
៩-២ រឿងកបិលមហាព្រហ្ម ទេពធីតា៧អង្គ..................................៥៥
៩-៣ ប្រតិទិនបុណ្យទ្វាទសមាស ពីឆ្នាំ ២០១៥ ដល់ ២០២៤...៥៨
១០- អ្នកនិពន្ធ.................................................................. ៦០
១១- សៀវភៅ និង អត្ថបទយោង.............................................៦១

# ១- លំនាំដើម

តាមប្រពៃណីខ្មែរយើង បុណ្យទាំងឡាយ អាចចែកជាពីរពួក គឺ:

-បុណ្យផ្អែកពុទ្ធសាសនា ដូចជាបុណ្យមាឃបូជា វិសាខបូជា កឋិន ជាដើម និង

-បុណ្យផ្អែកប្រពៃណី ដូចជាចូលឆ្នាំ ឬភ្ជុំបិណ្ឌ។

បុណ្យនីមួយៗ ច្រើនចាប់ផ្តើម ពីម៉ោង១០ ព្រឹករហូតដល់ម៉ោង ១១ព្រឹក(១) ដោយមាន លោកអាចារ្យ ជាអ្នកណែនាំតាមកម្មវិធីរបស់អ្នកដើមបុណ្យ។ លោកអាចារ្យបន្ទាប់ពីរៀបចំផ្កាភ្ញីសមរម្យហើយនៅចំពោះព្រះភ័ក្ត្រព្រះពុទ្ធរូប ក៏អញ្ជើញ អ្នកដើមបុណ្យអុជទៀនធូប និង ពុទ្ធបរិស័ទព្រមទាំងញាតិមិត្តឲ្យតាំងសតិស្មារតី ហើយក៏ណែនាំចាប់ផ្តើមពិធីតាមលំដាប់ដូចតទៅនេះ ៖

១-នមស្សការព្រះរតនត្រ័យ ។

២-សមាទានសីល (មានសីល៥ជាដើម)។

៣-និមន្តព្រះសង្ឃចំរើនព្រះបរិត្ត ។

៤-ពុទ្ធបរិស័ទ នាំគ្នារាប់បាត្រ, (២)

---

(១)-អ្នកខ្លះគេនិមន្តព្រះសង្ឃចំរើនបរិត្តពីល្ងាចក៏មាន។

(២)-អ្នកខ្លះគេរាប់បាត្រ បើមិនរាប់បាត្រ គេអាចលើកចង្ហាន់មកវេរតែម្តងក៏បាន ។

**ក្នុងការរាប់បាត្រ តើត្រូវរាប់ពីណាទៅមុន ?**

<u>ឆ្លើយថា:</u>

ត្រូវរាប់ចាប់ពីព្រះសង្ឃដែលចាស់វស្សារៀងទៅ ព្រះសង្ឃចាស់វស្សា លោកគង់នៅដើមជិតព្រះពុទ្ធរូប ហើយព្រះពុទ្ធរូបនៅខាងស្តាំដៃលោក។ បើពុទ្ធបរិស័ទ ធ្វើបុណ្យនៅផ្ទះ ត្រូវរៀបចំកន្លែងតម្កល់ព្រះពុទ្ធរូបនិងកន្លែងព្រះសង្ឃទាំងឡាយគង់ទៅតាមរបៀប ខាងលើនេះ បើសិនជាអាចធ្វើទៅបាន ។

តែបើធ្វើមិនបាន ហើយផ្ទះចង្អៀត ឬ ខ្វះកន្លែងសមរម្យនោះ ក៏មិនអីដែរ ។

នៅកន្លែងខ្លះលុះបានរាប់គ្រប់បាត្រហើយ ពោលគឺបន្ទាប់ពីបានដាក់បាយក្នុងបាត្រចុងក្រោយគេហើយ..........

៥-លោកអាចារ្យ នាំពុទ្ធបរិស័ទ វេរកត្តប្រគេនព្រះសង្ឃ ហើយពុទ្ធបរិស័ទ ថាតាមអាចារ្យ,

៦-ប្រគេន ចង្ហាន់បិណ្ឌបាត និង ទេយ្យទានដល់ព្រះសង្ឃ,

៧-ព្រះសង្ឃស្មូត្រធម៌បង្សុកូល អនុមោទនា,

៨-ពុទ្ធបរិស័ទផ្សាយបុណ្យកុសលដល់អ្នកដ៏មានគុណព្រមទាំងពួកញាតិនិងសព្វសត្វទូទៅ ដោយស្មូត្រធម៌យំកិញ្ចិ.....ជាដើម ជាកិច្ចបញ្ចប់បុណ្យនៅពេលព្រឹក។ បើមានធម្មទេសនា លោកអាចារ្យជម្រាបដល់ពុទ្ធបរិស័ទថាមានធម្មទេសនានៅម៉ោង១៣.០០បន្ទាប់ពីពិសាចំណីអាហាររួចស្រេច(៣),

៩-ព្រះសង្ឃឆាន់ភោជនាហារពីម៉ោង១១ទៅដល់ម៉ោង១២។ ពីថ្ងៃត្រង់ទៅ ព្រះសង្ឃពុំអាចឆាន់ចំណីអាហារបានទេ ក្រៅពីភេសជ្ជៈ .

១០-បន្ទាប់មកពុទ្ធបរិស័ទក៏រៀបចំពិសាចំណីអាហារដែលអ្នកដើមបុណ្យបានរៀបចំទទួល ក្នុងបរិយាកាសរីករាយ ជាមិត្តភាព ជាភាតរភាព ។

១១-បើមានកម្មវិធីសំដែងធម៌ទេសនា(ស្រេចលើអ្នកដើមបុណ្យ) ព្រះសង្ឃនឹងសម្តែងធម៌ទេសនា នៅវេលាម៉ោង១៣.០០ ជាកិច្ចបញ្ចប់បុណ្យដោយបរិបូរណ៍ ។

---

អ្នករាប់បាត្រគេយកដៃចិបបាយបន្តិចដាក់ក្នុងកន្ទោងស្លឹកចេកដែលនៅបន្ទាប់ពីបាត្រចុងក្រោយបង្អស់គេហៅថា« **កន្ទោងបាយតារ** »។ បើអត់កន្ទោងស្លឹកចេក គេយកចានគោមជំនួសក៏បានដែរ។ កន្ទោងបាយតារនេះ ដល់ពេលចប់ពិធីរាប់បាត្រហើយគេយកម្ហូបនំ ចំណី មកថែមពីលើបាយដើម្បីទុកសម្រាប់អ្នកដើមបុណ្យ ដល់ពេលស្មូត្រធម៌យំកិញ្ចិ...ច្រួចទឹកក្នុងកន្ទោងបាយតារនោះដែលជាកិច្ចបញ្ជូនបាយទឹក នំចំណីនោះទៅឲ្យដល់ពពួកប្រេត។ លុះស្មូត្រយំកិញ្ចិ...ចប់ហើយគេយកកន្ទោងនោះទៅដាក់នៅក្រៅផ្ទះដូចជាគៀនរបងជាដើម ព្រោះថាពពួកប្រេតបើដាក់កន្លែងល្អពេកឬក៏ម្ហូបបាយទឹក រៀបចំដ៏សមរម្យពេកនោះ ប្រេតមិនអាចបរិភោគបានទេ។ នេះហេតុមកពីផលនៃកម្មដែលជា អកុសលរបស់ខ្លួនបានសាងទុកនោះ ។

(៣) ធម្មទេសនា មានសារៈសំខាន់ណាស់បើអាចធ្វើបាន គួរតែធ្វើ ។

*<u>សេចក្តីសង្កេត</u> :*

*បុណ្យខ្លះអាចធ្វើនៅពេលរសៀលបានហើយចាប់ពីម៉ោង១៤.០០ទៅ ដូចជាបុណ្យផ្កា ជាដើម។ ឯរបៀបនមស្សការព្រះរតនត្រ័យសមាទានសីលនិង ចំរើនព្រះបរិត្ត នៅដដែល តែបាលីវេរបុណ្យផ្កាខុសពីបាលីវេរកត្ថ។ ក្រៅពីបុណ្យផ្កា បុណ្យដែលអាចធ្វើពេល រសៀលបាន មានសូត្រមន្តឡើងផ្ទះ អាពាហ៍ពិពាហ៍ ឬ បង្សុកូល ឧទ្ទិសកុសលជូន អ្នកដែលទទួលអនិច្ចកម្មទៅហើយជាដើម។*

៙❃៚

## *<u>ការអានភាសាបាលី</u>*

*ដោយមានពាក្យត្អូញត្អែរពីអ្នកស្រុកខ្លះ ថាពិបាករៀនធម៌សូត្រថ្វាយបង្គំព្រះណាស់ ព្រោះមិនចេះអានភាសាបាលី ដោយហេតុនេះខ្ញុំសូមជូនការរៀនអានភាសាបាលី ជាមុនសិន មុននឹងទៅដល់ធម៌ថ្វាយបង្គំព្រះ ជាបន្ទាប់ ។*

*ចំពោះធម៌ថ្វាយបង្គំព្រះ ខ្ញុំចែកជាពីរផ្នែក គឺផ្នែក <u>ជាភាសាបាលីសុទ្ធ</u> និង ផ្នែកពន្យល់ ជាភាសាខ្មែរ ជាបន្ទាប់ ។*

*-មុនដំបូងលោកអ្នកអាចរៀនទន្ទេញ តែធម៌ដែលជាបាលីសិនក៏បានដែរ បើមានពេល ច្រើនទើបរៀនសូត្រធម៌ជាសំរាយបន្ថែមទៀតជាក្រោយ ។ គឺធម៌ជាបាលីនេះហើយ ដែលគេច្រើនសូត្រនៅតាមវត្ត ឬតាមផ្ទះ នៅពេលបុណ្យទានម្តងៗ ។ដូច្នេះខំរៀន អានបាលីសិនទៅ មិនជាពិបាកទេបើយើងចេះអានអក្សរខ្មែររួចហើយ ។*

## <u>២-ភាសាបាលីសរសេរជាអក្សរខ្មែរនិងអក្សរឡាតាំង</u>

### *<u>ក-ស្រៈនិស្ស័យភាសាបាលី</u>*

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| I | ា | ិ | ី | ុ | ូ | េ | ោ | ំ |
| a | ā | i | ī | u | ū | e | o | ṃ |

### *<u>ខ-ស្រៈនិស្ស័យភាសាខ្មែរ</u>*

| | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| I | ា | ិ | ី | ឹ | ឺ | ុ | ូ | ួ | ើ | ឿ | ៀ | េ | ែ | ៃ | ោ | ៅ | ុំ |
| a | ā | i | ī | ị | ḹ | u | ū | uo | oe | īoe | īe | e | ae | ai | o | au | uṃ |

ំ ាំ ះ ុះ េះោះ

aṃ āṃ aḥ uḥ eḥ oḥ

## គ-ស្រៈពេញតួ

អ អា ឥ ឦ ឧ ឩ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ អុំ អំ អាំ អះ

a ā i ī u ū ṛ ṝ Ḷ Ḹ ae ai o au uṃ aṃ āṃ aḥ

## ឃ-ព្យញ្ជនៈ

ក្ក ខ្ខ គ្គ ឃ្ឃ ង្ង ច្ច ឆ្ឆ ជ្ជ ឈ្ឈ ញ្ញ ដ្ដ ឋ្ឋ ឌ្ឌ ឍ្ឍ ណ្ណ ត្ត ថ្ថ ទ្ទ ធ្ធ ន្ន

k kh g gh ṅ c ch j jh ñ ṭ ṭh ḍ ḍh ṇ t th d dh n

ប្ប ផ្ផ ព្ព ភ្ភ ម្ម យ្យ ្រ ល្ល វ្វ ស្ស ហ្ហ ឡ្ឡ ំ (៤)

p ph b bh m y r l v s h ḷ ṃ

គេចែកចេញជាវគ្គ ដូចនេះ :

ក ខ គ ឃ ង = កវគ្គ

ច ឆ ជ ឈ ញ = ចវគ្គ

ដ ឋ ឌ ឍ ណ = ដវគ្គ

ត ថ ទ ធ ន = តវគ្គ

ប ផ ព ភ ម = បវគ្គ

យ រ ល វ ស ហ ឡ អ = សេសវគ្គ ។

## របៀបអានភាសាបាលី

អក្សរបាលី គេមិនអាន ក ខ គ ឃ ង ដូចភាសាខ្មែរយើងទេ

ក អានថា ក: ខ អានថា ខ: គ អានថា គ: ឃ អានថា ឃ: ង អានថា ង:

............. រៀងរហូតដល់ចប់។ ប៉ុន្តែ អក្សរ ប មិនអានថា ប: ទេ គេអានថា ប៉:។

---

(៤)- ំ (និគ្គហិត) សំរាប់ ដាក់ពីលើ ស្រ: អ អិ អុ ។

ំ ដាក់លើស្រ: អ (អំ) មើលថា អាំង

ំ ដាក់លើស្រ: អិ (អឹ) មើលថា អឹង

__១- បើអក្សររាយតួ__ ត្រូវអានគ្រប់តួអក្សរ ព្រោះមិនមានតួណាប្រកបឲ្យតួណាទេ

__ឧទាហរណ៍:__ សយនៈ ត្រូវអានថា សៈយៈនៈ អានថា សយនៈ មិនបានទេ ពហុល ត្រូវអានថា ពៈហុលៈ អានថា ពៈហុល មិនបានទេ។

__២- អក្សរតម្រួតគ្នា ហើយអក្សរតម្រួតនោះនៅក្នុងវគ្គជាមួយគ្នា__

អក្សរខាងលើគ្រាន់តែជាតួប្រកបអក្សរខាងដើម មិនអាចបញ្ចេញសម្លេងខ្លួនឯងបានទេ។ ចំណែកជើងអក្សរខាងក្រោមមានសិទ្ធិចេញសម្លេង និងប្រើប្រាស់ស្រៈខាងលើនោះផង

__ឧទាហរណ៍:__ សក្ក ត្រូវអានថា សាក់ កៈ គឺអាន__សង្កត់__ សាក់ ឲ្យធ្ងន់ នឹងអានថា សៈកៈ មិនបានទេឬ នឹងអានថា សៈកៈកៈមិនបានទេ ព្រោះអក្សរលើគ្រាន់តែតួប្រកប ប៉ុណ្ណោះ។ សច្ចិ ត្រូវអានថា សាច់ចិ នឹងអានថា សៈ ចិ ឬ សាច់ ចៈចិ មិនបានទេ។

__៣-អក្សរ វគ្គដទៃ តម្រួតលើអក្សរ សេសវគ្គ ក្តី អក្សរ សេសវគ្គ តម្រួតលើ អក្សរ វគ្គដទៃក្តី__

អក្សរខាងលើជាតួប្រកបអក្សរខាងដើមផង ជាតួគ្រវាត់ផ្សំជាមួយជើងខាងក្រោមផង

__ឧទាហរណ៍:__ សក្យ ត្រូវអានថា សាក់ ក្យៈ នឹងអានថា សៈ ក្យៈ ឬ សាក់ យៈ មិនបានទេ។ តត្រ ត្រូវអានថា តាត់ ត្រៈ នឹងអានថា តៈ ត្រៈ ឬ តាត់ រៈ មិនបានទេ។ កត្វា ត្រូវអានថា កាត់ ត្វា នឹងអានថា កៈ ត្វា ឬ កាត់ វ៉ា មិនបានទេ។ តណ្ហា ត្រូវអានថា តាន់ ណ្ហា នឹងអានថា តៈ ណ្ហា ឬ តាន់ ហា មិនបានទេ។ តស្មា ត្រូវអានថា តាស់ ស្មា នឹងអានថា តៈ ស្មា ឬ តាស់ ម៉ា មិនបានទេ។ កល្ប ត្រូវអានថា កាល់ ល្បៈ នឹងអានថា កៈ ល្បៈ ឬ កាល់ ប៉ៈ មិនបានទេ។

ំ ដាក់លើស្រៈ អុ (អុំ) មើលថា អុង ។

__ឧទាហរណ៍:__

ធម្មំ មើលថា : ធ័ម + មាំង /

បុណ្ណំ មើលថា : ប៉ុណ + ណាំង

វត្ថុំ មើលថា : វ័ត + ថុំង

វក្ខិតុំ មើលថា : វ័ក + ខិ + តុង

*៤- បើអក្សរសេសវគ្គ តម្រួតគ្នាឯង*

*-តួនិងជើងដូចគ្នា ដូចពាក្យថាអយ្យា តួលើគ្រាន់តែជាតួប្រកប មិនអាចបញ្ចេញសម្លេងបានទេ អយ្យា ត្រូវអានថា អ័យ យ៉ា នឹងអានថា អៈ យ៉ា ឬ អៈ យៈយ៉ា មិនបានទេ។*

*-អក្សរតម្រួតតួផ្សេងគ្នា(*) ដូចពាក្យ មយ្ហំ ត្រូវអានថា ម័យ ហ្យំ នឹងអានថា មៈហ្យំ ឬ ម័យ ហំ មិនបានទេ។ អស្វ ត្រូវអានថា អ័ស ស្វៈ នឹងអានថា អៈស្វៈ ឬ អ័ស វៈ មិនបានទេ។*

# ៣-នមស្សការ ព្រះរតនត្រ័យ

ធម៌ជាបាលី ពន្យល់ន័យ

**-នមោ តស្ស** *-ខ្ញុំសូមគោរព,*

**-ភគវតោ** *-ចំពោះព្រះមានព្រះភាគគឺថាព្រះអង្គលោកមានមេត្តាចែកភាគចំណែកធម៌មកឲ្យយើង,*

**-អរហតោ** *-ព្រះអង្គជាព្រះអរហន្ត គឺថា : ព្រះអង្គ ឆ្ងាយចាកកិលេស អស់គ្រឿងប្រឡាក់ ពីក្នុងព្រះទ័យព្រះអង្គហើយ,*

**-សម្មា សម្ពុទ្ធស្ស** *-ព្រះអង្គ ត្រាស់ដឹងដោយព្រះអង្គឯង ដ៏ប្រពៃ ។*

*បើនិយាយរួម នមោ តស្ស ភគវតោ អរហតោ សម្មា សម្ពុទ្ធស្ស គឺថា : ខ្ញុំសូមគោរពព្រះសម្មាសម្ពុទ្ធ ដែលមានគុណបីប្រការដោយសង្ខេប គឺ :*

*១-ភគវតោ : ចែកធម៌ដល់អ្នកដទៃ (**ជាករុណាគុណ**),*

*២-អរហតោ : ជាព្រះអរហន្ត ព្រះអង្គ អស់កិលេស ជា អ្នកមានសេចក្ដីស្អាត បរិសុទ្ធ (**ជាវិសុទ្ធិគុណ**),*

*៣-សម្មាសម្ពុទ្ធស្ស : ព្រះអង្គ ត្រាស់ដឹងដោយខ្លួនព្រះអង្គ ដ៏ប្រពៃ បានន័យថា ព្រះអង្គ មានប្រាជ្ញាល្អណាស់ (**ជាបញ្ញាគុណ**)។*

*រួមសេចក្ដីទៅ យើងថ្វាយបង្គំព្រះសម្មាសម្ពុទ្ធ គឺនឹកដល់ គុណទាំងបីខាងលើនេះ ។*

---

(*) *អក្សរខាងលើជាតួប្រកបអក្សរខាងដើមផង តួគ្រវាត់ផ្សំជាមួយជើងខាងក្រោមផង។*

## ៣-១ នមស្សការ ថ្វាយបង្គំព្រះពុទ្ធ

**-ឥតិបិសោ ភគវា** ខ្ញុំសូមថ្វាយបង្គំព្រះមានព្រះភាគអង្គនោះ ព្រះអង្គមានគុណ១០ប្រការៈ

**-អរហំ** ១-ព្រះអង្គឆ្ងាយចាកសិកសត្រូវ ពោលគឺ កិលេស ព្រមទាំងវាសនា គឺ កាយបយោគ និង វចីបយោគ

**-សម្មា សម្ពុទ្ធោ** ២-ព្រះអង្គ ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃ ចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណា ប្រដៅព្រះ អង្គ ឡើយ

**-វិជ្ជាចរណ សម្បន្នោ** ៣-ព្រះអង្គបរិបូណ៌ដោយវិជ្ជា៣ និងវិជ្ជា៨ និងចរណៈ ១៥

**-សុគតោ** ៤-ព្រះអង្គមានដំណើរល្អយាងទៅកាន់សុន្ទរដ្ឋាន គឺ អមត មហានិព្វាន,

**-លោក វិទូ** ៥-ព្រះអង្គជ្រាបច្បាស់នូវ ត្រៃលោក,

**-អនុត្ត រោ** ៦-ព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន

**-បុរិស ទម្ម សារថិ** ៧-ព្រះអង្គជាអ្នកទូន្មានទូវបុរស ដែលមានឧបនិស្ស័យ គួរនឹងទូន្មានបាន

**-សត្ថា ទេវ មនុស្សានំ** ៨-ព្រះអង្គ ជាសាស្តាចារ្យ នៃទេវតា និងមនុស្សទាំងឡាយ

**-ពុទ្ធោ** ៩-ព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ហើយញ៉ាំងអ្នកដទៃឲ្យត្រាស់ដឹងផង

**-ភគវា** ១០-ព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ចាក់ចោលហើយ គឺថា ព្រះអង្គមិនត្រឡប់កើត ទៀតឡើយ ។

**-តំ អរហាទិ គុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ** -ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គ ប្រកបព្រមហើយដោយគុណ មាន គុណថាអរហំជាដើម នោះ ដោយ សិរសា គឺត្បូង

**-តព្វ ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ** -ខ្ញុំព្រះករុណាសូមបូជាចំពោះ នូវព្រះសម្មាសម្ពុទ្ធជាម្ចាស់ អង្គនោះដោយគ្រឿងសក្ការទាំងឡាយមានប្រមាណ ប៉ុណ្ណេះ ។

**(ក្រាបថ្វាយបង្គំម្តង)**

## ៣-២ នមស្សការ ថ្វាយបង្គំ ព្រះធម៌

**-ស្វាក្ខាតោ ភគវតា ធម្មោ** -ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដក ជាធម៌ គឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយដោយល្អ

[(**-ធម្មោ**) -ព្រះនព្វលោកុត្តរធម៌ មាន ៩ ប្រការគឺ មគ្គ៤ ផល៤ និព្វាន១]

**-សន្ទិដ្ឋិកោ** -ជាធម៌ គឺព្រះអរិយបុគ្គលទាំងពួង ដឹងពិត ឃើញពិតដោយ បច្ចវេក្ខណញ្ញាណ គឺ ថានឹងបានដឹង ដោយស្តាប់ ដោយជឿបុគ្គលដទៃនោះៗ ក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង

**-អកាលិកោ** -ជាធម៌ឲ្យនូវផលមិនរង់ចាំកាល គឺថា បើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផល ក៏កើតក្នុងលំដាប់គ្នា មិនបានយឺតយូរឡើយ (គឺបដិបត្តិបានគ្រប់ពេល)

**-ឯហិបស្សិកោ** -ជាធម៌គួរដល់ឯហិបស្សវិធី គឺថាបើព្រះអរិយបុគ្គលដែលបានសម្រេច មគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដទៃឲ្យចូលមកមើលបាន (ឬ ពិសោធបាន)

**-ឱបនយិកោ** -ជាធម៌គឺព្រះអរិយបុគ្គល គប្បី បង្អោនចូលមកទុកក្នុងខ្លួន ដោយ អំណាចនៃភាវនា

**-បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** -ជាធម៌គឺអ្នកប្រាជ្ញទាំងឡាយ មានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹង គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន

**-តំ ស្វាក្ខាតាទិគុណយុត្តំ ធម្មំ សិរសា នមាមិ** -ខ្ញុំព្រះករុណាសូមថ្វាយបង្គំ នូវព្រះធម៌ជាម្ចាស់ ដ៏ប្រកបព្រមហើយ ដោយគុណ មានគុណថាស្វាក្ខាតោ ជាដើមនោះ ដោយសិរសា គឺត្បូង

**-តព្វូ ធម្មំ ឥមេហិ សក្ការេហិ អភិបូជយាមិ** -ខ្ញុំព្រះករុណា សូមបូជាចំពោះ នូវព្រះធម៌ ជាម្ចាស់ ដោយគ្រឿងសក្ការៈ ទាំងឡាយ មានប្រមាណ ប៉ុណ្ណេះ ។

ក្រាបថ្វាយបង្គំម្តង)

## ៣-៣- នមស្សការ ថ្វាយបង្គំ ព្រះសង្ឃ

**-សុបដិបន្នោ ភគវតោ សាវក សង្ឃោ** -ព្រះសង្ឃជាសាវកនៃព្រះដ៏មាន ព្រះភាគ លោកប្រតិបត្តិហើយ ដោយប្រពៃ គឺប្រតិបត្តិតាមគន្លង ព្រះនព្វលោកុត្តរធម៌

**-ឧជុ បដិបន្នោ ភគវតោ សាវកសង្ឃោ** -ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគលោក ប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមប្បដិបទា

**-ញាយបដិ បន្នោ ភគវតោ សាវកសង្ឃោ** -ព្រះសង្ឃជាសាវកនៃព្រះដ៏មាន ព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ជាស្ពានក្សេម ផុតចាកទុក្ខទាំងពួង

**-សាមីចិបដិ បន្នោ ភគវតោ សាវកសង្ឃោ** -ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិ គួរដល់ សីល សមាធិ បញ្ញា

**-យទិទំ ចត្តារិ បុរិសយុគានិ** -ព្រះសង្ឃ ឯណាបើរាប់ជាគូនៃ បុរសទាំងឡាយមាន ៤គូ គឺព្រះសង្ឃដែលបានសម្រេចនូវ សោតាបត្តិមគ្គនិង សោតាបត្តិផល ជាគូ ១, សកទាគាមិមគ្គ និង សកទាគាមិផល ជាគូ ១, អនាគាមិមគ្គ និង អនាគាមិផល ជាគូ ១, អរហត្ត មគ្គ និង អរហត្តផល ជាគូ១,

**-អដ្ឋ បុរិស បុគ្គលា** -បើរាប់រៀងជាបុរសបុគ្គលមាន៨គឺ ព្រះសង្ឃដែលបានសម្រេចនូវ សោតាបត្តិមគ្គ ១, សោតាបត្តិផល ១, សកទាគាមិមគ្គ ១, សកទាគាមិផល១, អនាគាមិមគ្គ១, អនាគាមិផល១, អរហត្តមគ្គ១,អរហត្តផល១

**-ឯស ភគវតោ សាវកសង្ឃោ** -ព្រះសង្ឃទាំងនុ៎ះជាសង្ឃសាវក នៃព្រះដ៏មានព្រះភាគ

**-អាហុ នេយ្យោ** -លោកគួរទទួលនូវចតុប្បច្ច័យដែល បុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកអំពីចម្ងាយ បង្អោនចូល មកបូជា

**-បាហុនេយ្យោ** -លោកគួរទទួលនូវអាគន្តុកទានគឺទានដែលបុគ្គលតាក់តែងដើម្បីញាតិនិង មិត្រដែលមកអំពីទិសផ្សេងៗ ហើយបង្អោនចូលមកបូជា

**-ទក្ខិ ណេយ្យោ** -លោកគួរទទួលនូវទានដែលបុគ្គល ជឿនូវកម្ម និងផលនៃកម្ម ហើយ បូជា,

**អញ្ជលិ ករណីយោ** -លោកគួរដល់អញ្ជលីកម្ម ដែលសត្វលោកគប្បីធ្វើ

**-អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ** -លោកជាបុញ្ញក្ខេត្ត គឺជាទី ដុះឡើងនៃពូជគឺបុណ្យនៃសត្វលោក រកខេត្តដ៏ទៃក្រៃលែងជាងគ្មាន

**-តំ សុបដិបន្នា ទិគុណសំយុត្តំ សង្ឃំ សិរសា នមាមិ**-ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះសង្ឃជាម្ចាស់ ដ៏ប្រកបព្រមហើយដោយគុណមានគុណថា សុបដិបន្នោ ជាដើមនោះ ដោយសិរសាគឺត្បូង

**-តញ្ច សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ** -ខ្ញុំព្រះករុណាសូមបូជាចំពោះនូវ ព្រះសង្ឃជាម្ចាស់ ដោយគ្រឿងសក្ការៈទាំងឡាយមានប្រមាណប៉ុណ្ណេះ ។

(ក្រាបថ្វាយបង្គំម្តង)

## ថ្វាយបង្គំសូមសេចក្តីសុខ

**ឥច្ចេវមច្ចន្ត នមស្សនេយ្យំ នមស្សមានោ រតនត្តយំ យំ បុញ្ញាភិសន្ទំ វិបុលំ**
**អលត្ថំ តស្សានុភាវេន ហតន្តរាយោ ។**

ខ្ញុំសូមនមស្សការ លើកហត្ថាឱនសិរសី បង្គំគុណទាំងបី ខ្ពស់លើសលប់ត្រៃលោកា។
សូមបុណ្យកុសល ឱ្យបានដល់យើងខ្ញុំណា ពេញពោរស្មើធារា
ដូចជលសាធំទូលាយ។
សូមឱ្យកំចាត់បង់ អពមង្គលទាំងឡាយ ឱ្យចៀសចេញចាកឆ្ងាយ ក្តីអន្តរាយកុំបីមាន។
ដោយកំឡាំងអានុភាព បុញ្ញលាភជាប្រធាន កងបុញ្ញរាសីមាន
សូមបានក្សាន្តកុំមានមោះ។
ដោយគុណនមស្ការ ត្រៃរតនាប្រសើរខ្ពស់ សូមអានិសង្សនោះ
ដាក់ដល់ឋាននិព្វានហោង ។ៗ

(ក្រាបថ្វាយបង្គំ ៣ ដង)

(ចប់ថ្វាយបង្គំព្រះរតនត្រ័យ)

# ៤- សមាទាន សីល ៥ (និច្ចសីល)

*សីល៥ មនុស្សក្នុងដែនកុរុគេរក្សាយូរណាស់មកហើយ ព្រះពុទ្ធទទួលយកសីល៥នេះមកប្រើ ហៅថានិច្ចសីល គឺសីលដែលគេត្រូវរក្សាជានិច្ច ។*

**-ឱកាស មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ច សីលានិ យាចាម**(៣)។

*-ពាក្យអារាធនាថា:សូមគោរព បពិត្រ ព្រះករុណាដ៏ចំរើន ខ្ញុំព្រះករុណាសូមនូវសីលទាំងឡាយ៥ មួយអន្លើ ដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍ និងរក្សាផ្សេងៗគ្នា ។*

**-ទុតិយម្បិ មយំភន្តេ..ៗ** *-ជាគម្រប់ពីរដងផង... ។*

**-តតិយម្បិ មយំភន្តេ..ៗ** *-ជាគម្រប់បីដងផង... ។*

*ព្រះសង្ឃអ្នកឲ្យសីលនាំថា ហើយអ្នកកាន់សីល ត្រូវថាតាម*

**នមោ តស្ស... (៣ដង) ៗ** *-ដូចមានពន្យល់ខាងដើម រួចមក ហើយ ។*

**-ពុទ្ធំ សរណំ គច្ឆាមិ** *-ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធ ជាទីពឹងទីរលឹក*

**-ធម្មំ សរណំ គច្ឆាមិ** *-ខ្ញុំព្រះករុណាសូមដល់នូវព្រះធម៌ ជាទីពឹងទីរលឹក*

**-សង្ឃំ សរណំ គច្ឆាមិ** *-ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃ ជាទីពឹងទីរលឹក*

**-ទុតិយម្បិ...ៗ** *-ជាគម្រប់ពីរដងផង... ។*

**-តតិយម្បិ...ៗ** *-ជាគម្រប់បីដងផង... ។*

*ព្រះសង្ឃថា*: **តិសរណគ្គហនំ បរិបុណ្ណំ**

*កិរិយាកាន់យកនូវព្រះត្រៃសរណគមន៍បរិបូណ៌តែប៉ុណ្ណេះ ។*

*អ្នកកាន់សីលទទួលថា:* **អាម ភន្តេ** *ករុណា លោកម្ចាស់ ។*

**ព្រះសង្ឃ នាំថា សិក្ខាបទមួយៗ**

**-បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ** *ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ បេតនាជាហេតុ វៀរចាកកិរិយា ធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។*

---

(៣) *បើ១នាក់ ប្រើ* **អហំ** *ជំនួស មយំ -* **យាចាមិ** *ជំនួស យាចាម ។*

**-អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ** -ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុ វៀរចាកកិរិយាកាន់យកនូវវត្ថុ ដែលគេមិនបានឲ្យដោយកាយ ឬដោយវាចា។

**-កាមេសុ មិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ**-ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទគឺចេតនា ជាហេតុវៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ។

**-មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ** -ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនា ជាហេតុវៀរចាកកិរិយាពោលនូវពាក្យកុហក។

**សុរាមេរយមជ្ជប្បមា ទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ** ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក ហេតុជាទីតាំងនៃសេចក្តីប្រមាទគឺផឹកនូវទឹកស្រវឹង គឺ សុរា និង មេរ័យ៕

## ៥- សមាទាន ឧបោសថសីល (សីល៨)

សីល៨ ពុទ្ធបរិស័ទជាគ្រហស្ថ ទទួលកាន់យកនៅថ្ងៃសីល (ថ្ងៃ៨កើត ៨រោច ១៥កើត ១៥រោច) ហៅថាថ្ងៃឧបោសថ ខុសប្លែកអំពីសីល៥ត្រង់ សិក្ខាបទ៣ថែមទៀតលើសពីសីល៥ ដូចជា វៀរ ហូបបាយពេលល្ងាច ឬសេពនូវ មេថុនធម្ម។ ដោយបាលីខាងដើមដូចគ្នា ខុសតែសីល៥ ជំនួសជាពាក្យ សីល៨ ខ្ញុំសូមលើកយកតែពាក្យប្រៀនប្រដៅទាំង៨ ដូចតទៅនេះ ៖

**-បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ៚** -ប្រែដូច និច្ចសីល ។

**-អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ៚** -ប្រែដូច និច្ចសីល ។

**-អព្រហ្មចរិយា វេរមណី សិក្ខាបទំ សមាទិយាមិ៚** -ខ្ញុំព្រះករុណាសូមសមាទាន នូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាប្រព្រឹត្តនូវធម៌មិនប្រសើរ គឺសេពនូវមេថុនធម្ម។

**-មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ៚** -ប្រែដូច និច្ចសីល ។

**-សុរាមេរយ មជ្ជប្បមា ទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ៚** -ប្រែដូច និច្ចសីល ។

**-វិកាល ភោជនា វេរមណី សិក្ខាបទំ សមាទិយាមិ៚** -ខ្ញុំព្រះករុណាសូមសមាទាន

*នូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាបរិភោគនូវភោជនាហារ ក្នុងកាលខុស ។*

**-នច្ចគីតវា ទិតវិសូ កទស្សនមាលាគន្ធ វិលេ បនធា រណមណ្ឌនវិភូ សនដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ។** *-ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទគឺចេតនាជាហេតុវៀរចាកកិរិយារាំនិងច្រៀងនិងប្រគំ និងមើលនូវល្បែងដែលជាសត្រូវដល់កុសលធម៌ និងកិរិយាទ្រទ្រង់ និងប្រដាប់តាក់តែងស្អិតស្អាងរាងកាយដោយផ្កាកម្រង និងគ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ។*

**-ឧច្ចា សយន មហា សយនា វេរមណី សិក្ខាបទំ សមាទិយាមិ។**

*-ខ្ញុំព្រះករុណាសូមសមាទាន នូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកទីសេនាសនៈដ៏ខ្ពស់ហួសប្រមាណ និងទីសេនាសនៈ ដ៏ប្រសើរ។*

*បន្ទាប់មក អ្នកសមាទាន សូត្រជាបាលី និង សម្រាយ ដូច តទៅនេះ ៖*

**ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធបញ្ញត្តំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សម្មទេវ អភិរក្ខិតុំ សមាទិយាមិ។**

*ខ្ញុំព្រះករុណាសូមសមាទាននូវឧបោសថសីលដ៏ប្រកបព្រមដោយអង្គ៨ ដែល ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់បញ្ញត្តទុកហើយនេះ ដើម្បីនឹងរក្សាឲ្យបរិបូណ៍ប្រពៃអស់កាលកំណត់ថ្ងៃនេះនិងយប់នេះ សូមកុសលចូរជាឧបនិស្ស័យធ្វើឲ្យច្បាស់នូវព្រះនិព្វានពួដ៏អនាគតទៅឯមុខ នោះហោង ។*

# ៦- កិច្ចវេរសង្ឃភត្ត

[**-អយំនោ ភន្តេ**] [**បិណ្ឌបាតោ**] [**ធម្មិកោ**] [**ធម្មលទ្ធោ**] [**ធម្មេនេវ ឧបាទិតោ**]

*បពិត្រព្រះគម្ពែងសង្ឃ ដ៏ចំរើនអើយ រីចង្ហាន់បិណ្ឌបាត នៃយើងខ្ញុំទាំងឡាយនេះ ប្រកបដោយធម៌ បានមកដោយធម៌ កើតឡើងដោយធម៌*

[**-មាតាបិតុ អាទិកេ**] [**គុណវន្តេ ឧទ្ទិស**] *-យើងខ្ញុំទាំងឡាយសូមឧទ្ទិសចំពោះដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើម*

[**-ឥមំ (សង្ឃភត្តំ)**] [**សបរិក្ខារំ**] [**ពុទ្ធប្បមុខស្ស**] [**សង្ឃស្ស ទេម**] [**តេ គុណវន្តា នយោ**]

*-យើងខ្ញុំទាំងឡាយសូម (វេរនូវសង្ឃភត្តនេះ) ព្រមទាំងបរិក្ខារ ប្រគេនដល់ព្រះសង្ឃមានព្រះពុទ្ធរូបស្នង ព្រះអង្គជាប្រធាន*

[**-ឥមំ (សង្ឃភត្តំ)**] [**អត្តនោ សន្តកំ វិយ**] [**មញ្ញមានា**] [**អនុមោទន្តុ**] [**អនុមោទិត្វាន**] [**យថិច្ឆិត សម្បត្តីហិ**] [**សមិជ្ឈន្តុ**] [**សព្វទុក្ខា បមុញ្ចន្តុ**] [**ឥមិនា និស្សន្ទេន**]**ៗ**

*-សូមលោកអ្នកដ៏មានគុណទាំងឡាយមានមាតានិងបិតាជាដើមនោះ សំគាល់នូវ(សង្ឃភត្ត)នេះ ថាដូចជារបស់នៃខ្លួន ហើយសូមអនុមោទនាយកចុះ លុះអនុមោទនារួចហើយ សូមឲ្យរួចរំដោះ ចាកទុក្ខទាំងពួង ឲ្យបានសម្រេចដោយសម្បត្តិទាំងឡាយបីប្រការ គឺៈ សម្បត្តិមនុស្ស១ សម្បត្តិទេវតា១ សម្បត្តិព្រះនិព្វាន១ ដោយសមគួរតាមសេចក្តីប្រាថ្នា របស់លោកអ្នក ដ៏មានគុណទាំងឡាយនោះចុះ ដោយអំណាចផលានិសង្ស ដែលហួរជូនទៅ មិនដាច់នេះហោងៗ*

[**ទុតិយម្បិ...ៗ**] *-អស់វារៈពីរដងផង... ៗ* [**តតិយម្បិ...ៗ**] *-អស់វារៈបីដងផង... ៗ*

# *៧- ធម៌ផ្សាយចំណែកបុណ្យ*

## **បត្តិទានគាថា**

*មុននឹងចប់ពិធីបុណ្យ គេតែងសូត្រធម៌ផ្សាយចំណែកបុណ្យ ជូន លោក អ្នក មានគុណមាន មាតាបិតា ជីដូន ជីតា និង ញាតិមិត្រ ជាដើម ដូចតទៅនេះ ៖*

**-យំកិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម** *-អំពើជាកុសល ឯណាមួយ ដែលខ្ញុំ គប្បីធ្វើ, ដោយទ្វារទាំង៣ គឺ*

**កាយេន វាចា មនសា** *-កាយ វាចា ចិត្ត,*

**-តិទសេ សុគតំ កតំ** *-អំពើ ជាកុសលទាំងអស់នោះ ដែលខ្ញុំបានធ្វើហើយ អាចនឹងនាំឲ្យទៅកើតក្នុងស្ថានត្រៃត្រឹង្ស ស្ួគ៌ បាន*

**-យេ សត្តា សញ្ញិនោ អត្ថិ** *-សត្វទាំងឡាយឯណា គឺ មនុស្ស ឬ ទេវតា ឬព្រហ្ម ដែលជាសត្វមានសញ្ញាក្តី,*

**-យេ ច សត្តា អសញ្ញិនោ** *-សត្វទាំងឡាយឯណាជា អសញ្ញីសត្វគឺសត្វដែលឥតសញ្ញាក្តី,*

**-កតំ បុញ្ញ ផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ** *-សត្វទាំងឡាយទាំងអស់នោះ*

ចូរបាននូវចំណែកផលនៃបុណ្យ ហើយចូរសោយនូវផល នៃបុណ្យដែលខ្ញុំបានធ្វើហើយ បានឧទ្ទិសផ្សាយឲ្យទៅនោះចុះ

**-យេតំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា** -បុណ្យដែលខ្ញុំបានធ្វើហើយនោះ បើសត្វទាំងឡាយឯណាបានដឹងច្បាស់ហើយ សត្វទាំងឡាយនោះ ចូរឲ្យបានសោយនូវផលបុណ្យ ដែលខ្ញុំ បានឧទ្ទិសឲ្យទៅនោះចុះ,

**-យេ ច តត្ថ ន ជានន្តិ** -ម្យ៉ាងទៀតបណ្តាអស់សត្វទាំងនោះ បើសត្វទាំងឡាយឯណាមិនបានដឹងនូវបុណ្យដែលខ្ញុំបានធ្វើហើយនោះ

**-ទេវា គន្ធា និវេទយ្យុំ** -សូមទេវតាទាំងឡាយអញ្ជើញទៅឲ្យដំណឹងដល់សត្វទាំងឡាយនោះឲ្យបានដឹងផង ថាជនឯណោះគេបានធ្វើបុណ្យ ហើយគេឧទ្ទិសផ្សាយផលបុណ្យនោះមកដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរអនុមោទនាត្រេកអរនឹងបុណ្យគេនោះចុះ

**-សព្វេ លោកម្ហិ យេ សត្តា ជីវន្តា ហារហេតុកា** -សត្វទាំងឡាយឯណាក្នុងលោកទាំងអស់ ដែលអាស្រ័យនូវអាហារ ហើយរស់នៅ

**-មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសាតិ ។** -សត្វទាំងឡាយទាំងអស់នោះ ចូរឲ្យបាននូវភោជនជាទីគាប់ចិត្ត ដែលសម្រេចដោយបុញ្ញឫទ្ធិតាមចិត្តខ្ញុំ ដែលឧទ្ទិសផ្សាយឲ្យទៅនោះចុះ ។

## តេជះខ្ញុំសាង

តេជះខ្ញុំសាង សំអិតសំអាង ឱនកាយវាចា សូមសុខសភាព រួចពីទុក្ខា
ឆ្លងដល់ត្រើយមហា ពោលគឺនិព្វាន ។

គ្រប់ជាន់គ្រប់ជាតិ កុំឲ្យខ្ញុំឃ្លាត ពីសីលនិងទាន គំនិតខ្ញុំកើត កំណើតខ្ញុំមាន
មគ្គផលជាស្ពាន ដល់ស្ថានថ្ងៃថ្លា ។

ខ្ញុំជូនមគ្គផល ចំពោះទៅដល់ មាតាបិតា គុណគ្រូឧប- ជ្ឈាយាចារ្យ គុណញាតិកា
ប្រាំពីរសន្តាន ។

ជីដូនជីតា រស់នៅក្តីណា លោកម្ចាស់បែកស្ពាន ខ្ញុំជូនមគ្គផល កុសលថ្កើងថ្កាន
សូមសុខក្សេមក្សាន្ត ដល់ស្ថានផុតទុក្ខ ៕

# ៨- ពិធីបុណ្យផ្សេងៗ តាមទំនៀមទម្លាប់ និង បុណ្យពុទ្ធសាសនា

## ៨-១ បុណ្យប្រពៃណី

### ៨-១-១ ពិធី ចំរើនបរិត្ត

កិច្ចចំរើនបរិត្ត ដែលអ្នកផងហៅថាសូត្រមន្តនោះ ពុទ្ធសាសនិកជន តែងធ្វើតាមពេលត្រូវការ ឬក៏ដើម្បីបានសេចក្តីសុខចំរើនសិរីសួស្តី ដូចជា សូត្រមន្តឡើងផ្ទះថ្មីឬសូត្រមន្តពេលរៀបអាពាហ៍ ពិពាហ៍ ជាដើមៗ ដើម្បីសូត្រមន្តត្រូវ ៖

១-និមន្តព្រះសង្ឃ ទុកជាមុន (៥)

២-រៀបចំផ្ទះសម្បែងឬទីកន្លែងដែលត្រូវសូត្រឲ្យមានរបៀបរៀបរយៗ

បើសូត្រនៅផ្ទះត្រូវតាំងអាសនៈនៃព្រះពុទ្ធរូប ដោយគ្រឿងសក្ការៈបូជា មានធូបផ្កាជាដើម មានផ្តិលទឹកព្រះបរិត្តដែលមានគ្រឿងអប់ឬផ្កាដ៏មានក្លិនក្រអូបក្នុងនោះសំរាប់ព្រះសង្ឃបាចទឹកទៅលើពុទ្ធបរិស័ទទាំងឡាយ ។

៣-បន្ទាប់ពីចាត់ចែងភេសជ្ជៈប្រគេនព្រះសង្ឃ ឧបាសកជាប្រធានក្នុងការសូត្រព្រះបរិត្ត គប្បីផ្តើមអុជទៀនធូបនៅទីទាំងពួងដែលគួរអុជ មានអាសនតាំងព្រះពុទ្ធរូបជាដើមហើយ ផ្តើមសូត្រនមស្សការព្រះរតនត្រ័យៗ ឧបាសកទាំងពួងគប្បីសូត្រជាមួយគ្នា ដោយ បញ្ចេញសំឡេង ។

៤-បន្ទាប់ពីនមស្សការ ព្រះរតនត្រ័យ រួចហើយ មានសមាទានសីល៥ ។

៥-បន្ទាប់ពីសមាទានសីលរួចហើយ ឧបាសកម្នាក់អារាធនាព្រះសង្ឃសូត្រព្រះបរិត្ត ជាពាក្យបាលី ថា៖

(៥)-គ្រប់បុណ្យទាំងអស់ ធ្វើនៅផ្ទះក្តី ឬ ធ្វើនៅវត្តក្តី ដែលត្រូវមានព្រះសង្ឃជាអធិបតី អ្នកផ្តើមបុណ្យ ត្រូវនិមន្តព្រះសង្ឃ ទុកមុន ជានិច្ច ។

**វិបត្តិបដិពាហាយ សព្វសម្បត្តិសិទ្ធិយា សព្វទុក្ខវិនាសាយ បរិត្តំ ព្រូថ មង្គលំ**

**វិបត្តិបដិពាហាយ សព្វសម្បត្តិសិទ្ធិយា សព្វភយវិនាសាយ បរិត្តំ ព្រូថ មង្គលំ**

**វិបត្តិបដិពាហាយ សព្វសម្បត្តិសិទ្ធិយា សព្វរោគវិនាសាយ បរិត្តំ ព្រូថ មង្គលំ ។**

*ពន្យល់ន័យ*

សូមព្រះករុណាទាំងឡាយចំរើន នូវព្រះបរិត្ត ជាជ័យមង្គល ដើម្បីនឹង ការពារ បញ្ចៀសនូវ វិបត្តិ គឺសេចក្តីអន្តរាយទាំងពួង ដើម្បីឲ្យបានសម្រេចនូវសម្បត្តិគ្រប់យ៉ាង ដើម្បី -**ញុាំង ទុក្ខ** -**ញុាំង ភ័យ** -**ញុាំង រោគ** ទាំងអស់ ឲ្យវិនាសបាត់ទៅ ។

៦-បន្ទាប់ពីនេះទៅ ព្រះសង្ឃ លោកចាប់សូត្រព្រះបរិត្ត

៧-លុះចប់កិច្ចចំរើនព្រះបរិត្តហើយ អ្នកម្ចាស់ទាន គប្បីបង្អោនទេយ្យទាន ទៅប្រគេន ព្រះសង្ឃ

៨-លុះប្រគេនទេយ្យទាននិងបរិក្ខារណាចតុប្បច្ច័យហើយព្រះសង្ឃលោកសូត្រអនុមោទនា។ ចប់អនុមោទនាហើយឧបាសក សូត្រ យំ កិញ្ចិ... ឧទ្ទិសផល ជាកិច្ចបញ្ចប់បុណ្យ ៕

## ៨-១-២ បុណ្យទក្ខិណានុប្បទាន

បុណ្យទក្ខិណានុប្បទានតាមទម្លាប់អ្នកស្រុកហៅថា"**បុណ្យតារ**"ព្រោះសម័យបុរាណព្រះសង្ឃដែលនិមន្តសូត្រក្នុងពេលនោះតែងសូត្រ "**ធម៌ពិស្តារ**" ដល់ហៅកាត់តែអក្សរមួយតួខាងចុងថា "ធម៌តារ" ។

បុណ្យតារគេធ្វើដោយវេរចង្ហាន់ប្រគេនព្រះសង្ឃ ឧទ្ទិសផលបញ្ជូនទៅបុគ្គលដែលស្លាប់ ។ បុណ្យនេះគេតែងធ្វើនៅពេលដែលបុគ្គលជាញាតិមានមាតាបិតាជាដើម ស្លាប់ថ្មីៗ ។ រាល់ឆ្នាំទៅមុខទៀតគឺធ្វើ១ខួបម្តង ចំលើថ្ងៃដែលបុគ្គលនោះស្លាប់ ឬថ្ងៃណាមួយ ក្បែរថ្ងៃគាត់ស្លាប់។ ពិធីបុណ្យចាប់ពីម៉ោង១០ព្រឹកទៅ មាន៖

១-នមស្សការ ព្រះរតនត្រ័យ

២-សមាទានសីល

៣-វេរភត្ត (មតកភត្ត) ដោយអាចារ្យ

៤-ប្រគេនចង្ហាន់និងទេយ្យទានដល់ព្រះសង្ឃ ដោយអ្នកផ្តើមបុណ្យ,

៥-ព្រះសង្ឃបង្សុកូលសូត្រកត្តានុមោទនា តាមទម្លាប់ ដែលធ្លាប់សូត្រ,

៦-កិច្ចឧទ្ទិសផល (សូត្រ យំ កិញ្ចិ... ) ដោយទាយក ទាយិកា និង អ្នកផ្តើមបុណ្យ ៕

(ចប់បុណ្យទក្ខិណានុប្បទាន)

## ៨-១-៣ បុណ្យផ្កា

បុណ្យដែលធ្វើដោយ មានផ្កា ជាសម្ភារៈ ហៅថា បុណ្យផ្កា ដោយគេសន្មតថា ប្រាក់ជាផ្កា យកមកបវារណា ចំពោះព្រះសង្ឃ ដើម្បីសាងអ្វីមួយ ដូចជា កុដិ វិហារ សាលាបុណ្យ សាលារៀន ស្ពាន ស្រះ ជាដើម ដែលជាការ សាងទាំងខាង ពុទ្ធចក្រ ទាំងខាងអាណាចក្រ ជាប្រយោជន៍ ធ្វើឲ្យជាតិ និង សាសនា រុងរឿង ។ ដោយការកសាងខ្វះត្រូវចាយប្រាក់រាប់ពាន់ រាប់ម៉ឺន ដោយធនធានមានតិច អ្នកមានសទ្ធា មិនអាចសាងម្នាក់ឯងកើត ក៏ផ្តើមជាបុណ្យផ្កាឡើងដើម្បីអង្គាសប្រាក់និងបបួលញាតិមិត្ត ឲ្យចូលរួមជួយកសាងថាវរៈវត្ថុនោះៗ ។

បុណ្យផ្កាអាចធ្វើបានគ្រប់ពេលវេលាមិនដូចបុណ្យកឋិនទេ។ អាចធ្វើចាប់ពីព្រឹកទៅក៏បាន ឬ ក៏ចាប់ធ្វើពីពេលរសៀល ក៏បាន ។

<u>កាតព្វកិច្ចនៃបុណ្យផ្កា</u>

១- កិច្ច សុំវត្តលោក ហែចូល

២- កិច្ច ផ្សាយដំណឹងបុណ្យផ្កា

៣-កិច្ចនមស្សការព្រះរតនត្រ័យ សមាទានសីលសូត្រព្រះបរិត្ត ទេសនា

៤- កិច្ច ដង្ហែ (ប្រសិនបើមានពិធីដង្ហែ)

៥- កិច្ច សូត្រសុន្ទរកថា

៦-កិច្ចវេរដោយប្រកាសថា“វេរប្រគេនព្រះសង្ឃ” បើធ្វើសាលារៀននៅក្នុងវត្តដែល ហែចូល ។

-បើប្រាក់ចំណូល សម្រាប់ធ្វើសាលារៀននៅវត្តផ្សេងពីវត្តហែចូល (ដូចជានៅស្រុកខ្មែរ ជាដើម) នោះគ្រាន់តែប្រកាសប្រាក់ចំណូលបានហើយ ។

៧- ប្រគេនបច្ច័យដល់ព្រះសង្ឃ

៨-កិច្ចឧទ្ទិសផល (សូត្រ យំកិញ្ចិ... ) ។

## ៨-១-៤ បុណ្យ បច្ច័យបួន

*បុណ្យដែលធ្វើដោយវេរបច្ច័យ (គ្រឿងអាស្រ័យរបស់បព្វជិត) គ្រប់ទាំងបួនមុខ ប្រគេនព្រះសង្ឃ ហៅថា បុណ្យបច្ច័យ ៤ ។*

*បច្ច័យ ៤ គឺអ្វីខ្លះ? បច្ច័យ ៤ គឺ ៖*

*១- គ្រឿងស្លៀកដណ្តប់ គឺស្បង់ ចីពរ សង្ឃាដី អង្សក វត្ថពន្ធ កន្ទេងដណ្តប់ កន្ទេងជូតមុខ ជាដើម ហៅថា* **ចីវរប្បច្ច័យ** *។*

*២- គ្រឿងឆាន់ គឺ បាយ សម្ល ម្ហូបក្រៀម ម្ហូបស្រស់ អំបិល ត្រីងៀត ត្រីឆ្អើរ ជាដើម ហៅថា* **បិណ្ឌបាតប្បច្ច័យ ។** *។*

*៣- គ្រឿង ដេក អង្គុយ មាន កន្ទេល ខ្នើយ មុង ឆ័ត្រ ស្បែកជើង កុដិ សាលា វិហារ តុ កៅអី ចានផ្តាំង ជាដើម ហៅថា* **សេនាសនប្បច្ច័យ** *។*

*៤- គ្រឿងថ្នាំព្យាបាលជម្ងឺ មានថ្នាំបុក គុលិកា ក្រមួនកុឡា ប្រេងខ្យល់ តែ ស្ករ ជាដើម ហៅថា* **គិលានភេសជ្ជប្បច្ច័យ** *។*

*ទាយកដែលធ្វើបុណ្យបច្ច័យ៤ត្រូវធ្វើគ្រប់ទាំង៤មុខ គឺគប្បីលៃធ្វើតាមសមត្ថភាពរបស់ខ្លួន បើអាចធ្វើប៉ុណ្ណាបានក៏ធ្វើប៉ុណ្ណោះ ទោះបីតិចតួច ឲ្យតែគ្រប់ទាំង៤ មុខ ដូចរៀបរាប់តទៅនេះ គឺ ៖*

*-មុខ គ្រឿង ចីវរ សូម្បីតែសាដក ១ ឬ ស្បង់ ១ ក៏បាន ។*

*-មុខគ្រឿងឆាន់សូម្បីតែចង្ហាន់១ចំអែតក៏បាន ។*

*-មុខគ្រឿងសេនាសនៈ សូម្បីតែ កន្ទេល១ ឬ ខ្នើយ១ ក៏បាន ។*

*-មុខគ្រឿង ភេសជ្ជៈ សូម្បីតែ ប្រេងខ្យល់ ១ ដប ក៏បាន ។*

*សូមជ្រាបថាបើធ្វើតូច ក្នុងបច្ច័យមួយៗក៏តិច តែទោះបីតិច ក៏គប្បីឲ្យគ្រប់៤មុខ ដូចពោលមកហើយ។ បើអាចធ្វើធំ ហើយក្នុងមួយមុខៗច្រើនបាន ក៏រឹតតែបានផលច្រើន ។*

*កាតព្វកិច្ច នៃ បុណ្យបច្ច័យ៤*

*១- ត្រូវនិមន្តព្រះសង្ឃទុក មុនថ្ងៃបុណ្យ*

២- ត្រូវរៀបចំទីសេនាសនៈ និង ទេយ្យទាន

៣- នមស្សការព្រះរតនត្រ័យ សមាទានសីល សូត្រមន្ត

៤- វេរបច្ច័យ ៤ និង ប្រគេនទេយ្យទាន

៥- ឧទ្ទិសផល (យំ កិញ្ចិ... )

៦- ធម្មទេសនា ។

<u>សេក្តីសង្កេត</u>

១-ការរៀបចំសេនាសនៈក្នុងពិធីបុណ្យបច្ច័យ៤ក៏ដូចក្នុងពិធីបុណ្យសង្ឃទានដែរ ប៉ុន្តែទេយ្យទាន គឺពិធីបុណ្យបច្ច័យ៤នេះ បើត្រូវធ្វើបច្ច័យធុនកណ្តាល ហើយបើនិមន្តព្រះសង្ឃ៤អង្គ (តាមនិយមគេនិមន្តព្រះសង្ឃ៤អង្គ) ត្រូវរៀបចំបច្ច័យនីមួយៗ ៤ប្រដាប់ សម្រាប់ប្រគេនលោក១ប្រដាប់ ១អង្គគឺ :

-មុខបិណ្ឌបាតប្បច្ច័យឲ្យមានបាយនិងម្ហូបបង្អែម

-មុខគិលានភេសជ្ជប្បច្ច័យត្រូវចងខ្ចប់ដោយក្រដាសភ្លឺៗចងបូរ ជាក្បាច់រំលេចពណ៌ឲ្យល្អស្អាត ហើយយកទាំង៤ ប្រដាប់នោះទៅតំកល់ចំពោះព្រះភ័ក្ត្រព្រះសង្ឃទាំង៤អង្គ នៅវេលាចម្រើនព្រះបរិត្ត ។

២-ចំពោះបុណ្យបច្ច័យ ៤ ត្រូវនិមន្តព្រះសង្ឃ <u>ជាសង្ឃមិនមែននិមន្តជាបុគ្គលទេ</u> ពោលគឺមិននិមន្តចំពោះតែអង្គណាមួយដោយបញ្ជាក់ព្រះនាមព្រះសង្ឃអង្គនោះទេ។

៣-គេអាចនិមន្តព្រះសង្ឃមកពីវត្តផ្សេងៗគ្នាក៏បាន ហើយគេអាចនិមន្តព្រះសង្ឃលើសពី៤អង្គបាន ឬក៏និមន្តព្រះសង្ឃតែមួយអង្គក៏បានដែរ ព្រោះសំខាន់លើបច្ច័យដែលត្រូវមាន ៤ មុខ ។

៤-គ្រឿងប្រដាប់ ៤មុខ បើអាចធ្វើបាន ៤ប្រដាប់ ក៏ធ្វើទៅ ឬបើគេមានទ្រព្យច្រើន ហើយអាចធ្វើបានលើសពី៤ប្រដាប់ក៏អត់ទំនាស់អីដែរ។

បើគ្មានយើងនិមន្តព្រះសង្ឃតែមួយអង្គក៏បានដែរតែត្រូវនិមន្តជាសង្ឃមិនមែននិមន្តជាបុគ្គល ទេ ។

៥-បើនិមន្តច្រើនអង្គហើយចង្ហាន់មានគ្រប់អង្គ តែប្រដាប់មានតែមួយគ្រឿងនោះក៏ហៅថា

បច្ច័យ៤ដែរ ព្រោះបច្ច័យមាន៤មុខរួចទៅហើយ គ្រាន់តែលោកមិនបាន មួយអង្គមួយប្រដាប់ៗបើលោកគង់នៅក្នុងវត្តតែមួយលោកអាចចែកគ្នាប្រើប្រាស់បានតែបើលោកនិមន្តមកពីវត្តផ្សេង ៗ គ្នា នោះពិបាកបន្តិច ។
៦-បុណ្យបច្ច័យ ៤ ច្រើនកូនចៅគេធ្វើជូនឪពុកម្តាយគេ ដើម្បីតបស្នងសងគុណគាត់ទាន់គាត់នៅមានជីវិតនៅឡើយគេអាចអញ្ជើញភ្ញៀវមកឲ្យបានកុះករដើម្បីឲ្យគាត់សប្បាយចិត្តៗតែកូនចៅត្រូវជំរាបគាត់ទុកជាមុនមិនត្រូវធ្វើដោយមិនឲ្យគាត់ដឹងជាមុននោះទេៗ បើកូនចៅគេមិនធ្វើឲ្យ យើងធ្វើខ្លួនយើង រៀងៗខ្លួន ជាការសន្សំបុណ្យ ក៏បានដែរ ។

## ៨-១-៥ បុណ្យភ្ជុំបិណ្ឌ

បុណ្យដែលគេបានដាក់បិណ្ឌឬកាន់បិណ្ឌ អស់ ១៤ ថ្ងៃ ចាប់ពីថ្ងៃ ១ រោច រហូតដល់ ១៤ រោច ខែភទ្របទ ហើយគេមកជួបជុំគ្នាប្រគេនចង្ហាន់ កាន់បិណ្ឌគឺកាន់យកប្រកាន់យក ទទួលយកថ្ងៃណាមួយដើម្បីប្រគេនបាយដល់ព្រះសង្ឃ ។
ចំណែកថ្ងៃចុងក្រោយបំផុតគឺថ្ងៃ១៥ រោច មិនឲ្យនរណាប្រកាន់យកទេ គឺត្រូវទុកជាថ្ងៃមកធ្វើរួមគ្នា ជួបជុំគ្នា ទើបគេឲ្យឈ្មោះថា ថ្ងៃ "ភ្ជុំបិណ្ឌ" (បុណ្យភ្ជុំបិណ្ឌ) ។
បុណ្យកាន់បិណ្ឌ (ពី១រោចទៅ១៤ រោច) និងភ្ជុំបិណ្ឌ(ថ្ងៃ១៥រោច) មានពិធីចំរើនបរិត្តរាប់បាត្រស្តាប់ធម៌ទេសនាដូចបុណ្យឯទៀតដែរៗ
ប៉ុន្តែមានលក្ខណៈពិសេសរបស់ខ្លួនដូចតទៅនេះ៖
១- ធ្វើបានតែក្នុងរនោចខែភទ្របទ ជាកំណត់,
២-ធ្វើដើម្បីឧទ្ទិសចំពោះអ្នកស្លាប់ជារឿងសំខាន់,
៣-ត្រូវតែមាន បាយដំណើប នំអន្សម នំគម
(ស្រុកខ្លះមានហៃបាយបិណ្ឌបោះបាយបិណ្ឌផង)
៤- ត្រូវតែសូត្របទ **បរាភវសូត្រ** ផង,
៥-ចំពោះថ្ងៃ១៤ រោច នៅតាមផ្ទះ គេវេចនំអន្សម នំគម ដើម្បីធ្វើបុណ្យ ធ្វើទានផង ។
៦-ចំពោះថ្ងៃ១៥រោចពេលព្រឹកគេធ្វើបុណ្យនៅវត្តពេលល្ងាច នៅតាមផ្ទះគេរៀបចំម្ហូប

ចំណីសែនដូនតា ហើយព្រឹកស្អែកឡើង គេជូនដំណើរដូនតា ត្រឡប់ទៅវិញ។

<u>សង្កេត</u> :

១-ក្នុងបាលីនិងអដ្ឋកថា មិនមាននិយាយរឿងភ្ជុំបិណ្ឌទេ ប៉ុន្តែមាននិយាយច្រើន រឿងបុណ្យឧទ្ទិសកុសល ចំពោះអ្នកស្លាប់ ។

២-មាននិទានមិនមែនតែក្នុងប្រទេសកម្ពុជាទេក្នុងប្រទេសឯទៀត ក៏មានដែរ តំណាលថា: នាយនិរយបាល បានបើកទ្វារឲ្យសត្វនរកប្រេតចេញទៅទទួលផលបុណ្យ ពីពួកញាតិមិត្រ ក្នុងរដូវវស្សា (រនោចខែភទ្របទ) ព្រោះសត្វ ពួកនោះ មានសេចក្តីភ័យខ្លាចច្រើនអែប ៗ តាមទីងងឹត។ តែប៉ុណ្ណោះ ។

៣-ក្នុងប្រទេសឯទៀតគេមានធ្វើបុណ្យឧទ្ទិសចំពោះអ្នកស្លាប់ក្នុងរដូវងងឹតដែរ ប៉ុន្តែគេធ្វើបុណ្យតែ ១ ថ្ងៃទេ ។

៤-សន្និដ្ឋានដោយមានហេតុដូចពោលហើយផងដោយក្នុងរដូវនោះ មានភ្លៀងមានទឹកច្រើនផងព្រះសង្ឃពិបាកបិណ្ឌបាតផង បានជាអ្នកប្រាជ្ញនិងអ្នកមានសទ្ធានាំគ្នាធ្វើបុណ្យកាន់បិណ្ឌភ្ជុំបិណ្ឌឡើង ។ តាមលទ្ធភាព គេអាចលៃធ្វើបុណ្យកាន់បិណ្ឌរាល់ថ្ងៃ ឬបន្ថយចំនួនថ្ងៃកាន់បិណ្ឌ និង ចំនួនព្រះសង្ឃដែលត្រូវវេន ទៅទទួលភត្ត ឲ្យសមល្មមតាមកម្លាំងរបស់គេបាន ។

ទិសដៅរបស់បុណ្យកាន់បិណ្ឌ ភ្ជុំបិណ្ឌ គឺដើម្បីមនុស្ស ស្លាប់ ច្រើនជាង មនុស្សរស់ ៕

## <u>៨-១-៦ បុណ្យចូលឆ្នាំខ្មែរ</u>

បុណ្យចូលឆ្នាំខ្មែរ មាន ៣ ថ្ងៃ។ នៅប្រទេសខ្មែរយើងទាំងរាជការទាំងប្រជារាស្ត្របានឈប់សំរាកអត់ធ្វើការងាររទេទាំង ៣ ថ្ងៃនេះ។ គេស្លៀកពាក់ខោអាវល្អៗ ដើរទៅវត្តឬទៅលេងស្រុកកំណើតជួបជុំបងប្អូន មីងមា ឪពុកម្តាយ ។

ថ្ងៃទី១ហៅថា“**មហាសង្ក្រាន**” ជាថ្ងៃដែលទេវតាថ្មីត្រូវវេន មករក្សាពិភពលោកយើងនេះ។ នៅថ្ងៃទី១នេះអ្នកស្រុកយកចង្ហាន់ បាយទឹកមកប្រគេនព្រះសង្ឃនៅឯវត្ត ហើយនៅពេលរសៀលគេនាំគ្នាលេងល្បែងប្រជាប្រិយ ដូចជាបោះឈូង បោះអង្គុញ់ជាដើម ។

ថ្ងៃទី២ ហៅថា "**វនប័ត**" ជាថ្ងៃដែលកូនចៅ យក អំណោយផ្សេងៗ មកជូនឪពុកម្តាយ ជីដូន ជីតា និងចាស់ព្រឹទ្ធាចារ្យ។ គេនាំគ្នាទៅវត្តដើម្បីពូនភ្នំខ្សាច់។

ថ្ងៃទី៣ ហៅថា"**ថ្ងៃឡើងស័ក**" ជាគម្រប់សង្ក្រាន្ត ៣ថ្ងៃ, ឆ្នាំថ្មីគឺចាប់ពីថ្ងៃទី៣នេះទៅ។ ឡើងស័ក បានន័យថា គេតម្លើងស័ក មួយឯកតា ឧបមា បើស័កឆ្នាំចាស់ ៩ ស័កឆ្នាំថ្មី ៩+១ =១០ ហើយបន្ទាប់ពី ១០ ទៅ គេត្រឡប់មកស័ក ដំបូងវិញ គឺស័ក ១ ហៅថា ឯកស័ក ។ ដូច្នេះ ស័ក មានទាំងអស់១០ គឺ : ឯកស័ក ទោស័ក ត្រីស័ក ចត្វាស័ក បញ្ចស័ក ឆស័ក សប្តស័ក អដ្ឋស័ក នព្វស័ក សំរិទ្ធិស័ក។

កត់សំគាល់នៅថ្ងៃឡើងស័កគឺស្រង់ព្រះ ស្រង់ភិក្ខុសង្ឃ ផ្លូតទឹកសំអាតខ្លួនប្រោណជូនឪពុកម្តាយ ជូនសំលៀកបំពាក់ថ្មីដល់គាត់ ហើយសូមខមាទោសគាត់ ចំពោះទោសដែលកូនបានធ្វើដោយភ្លាំងភ្លាត់ និងដើម្បី សម្តែងនូវកតញ្ញូតាធម៌ ចំពោះឪពុកម្តាយផង ។

<u>សេចក្តីសង្កេត</u> :

ជាទម្លាប់ ក្នុងឱកាសសង្ក្រាន្ត ទាំង៣ថ្ងៃ ប្រជាជនប្រុស ស្រី បានរៀបចំទេវតាពលី ទទួលស្វាគមន៍ ទេវតាឆ្នាំថ្មី និង អុជប្រទីបជ្វាលា ថ្វាយព្រះរតនត្រ័យហើយខិតខំលះបង់ចិត្តអាក្រក់ ទម្លាប់អាក្រក់ (ដូចជាជក់បារី ផឹកស្រា) ដែលធ្លាប់មានក្នុងឆ្នាំចាស់នោះឲ្យជ្រះស្រឡះ ។

យើងត្រូវតាំងចិត្តប្រព្រឹត្តអំពើល្អក្នុងឆ្នាំថ្មី ធ្វើបុណ្យដាក់ទានតាមប្រពៃណីរក្សាសីលឲ្យបានខ្ជាប់ខ្ជួន។ធ្វើយ៉ាងនេះយើងនឹងមានសិរីសួស្តីសុភមង្គលវិបុលសុខគ្រប់ប្រការត្រជាក់ត្រជុំអាយុយឺនយូរតរៀងទៅ ហើយទេវតាក៏លោកនឹងឲ្យពរសព្ទសាធុការដល់យើងដែរ។

## <u>៨-១-៧ មង្គលការ</u>

ដើម្បីជាពត៌មាន ខ្ញុំសូមលើកយកចំណុចធំៗ ខ្លះនៃមង្គលការ មករៀបរាប់ដូចតទៅនេះ ។ ពាក្យមង្គល មានន័យថា "សេចក្តីចំរើន សេចក្តីសុខ ហេតុដែលនាំឲ្យកើតសេចក្តីសុខ ចម្រើន សិរីសួស្តី" ។

ដូច្នេះ ការភ្ជាប់ សម្ព័ន្ធ ប្រុស និង ស្រី ឲ្យទៅជាប្ដីប្រពន្ធ ជាមង្គលមួយដែរ ហៅថា "មង្គលការ"។ គ្រួសារទាំងសង្ខាង(ទាំងខាងប្រុសទាំងខាងស្រី) ខំរៀបចំពិធីនេះឲ្យបានសមរម្យទៅតាមប្រពៃណីយើងផង និងឲ្យសមទៅតាម ក្អែកអ្នកទាំងពួងផង ។ មុននឹងទៅដល់ពិធីរៀបមង្គលការ មានការទាក់ទងចូលទៅស្ដីដណ្ដឹងមុនសិន ដូច្នេះតទៅនេះ ខ្ញុំសូមចែកអត្ថបទនេះ ជា ៣ ផ្នែក :

១- មុនមង្គលការ

២- មង្គលការ

៣- បន្ទាប់មង្គលការ។

## ១- មុនមង្គលការ

តាមទំនៀមទម្លាប់ខ្មែរយើង គឺប្រុសទៅដណ្ដឹងស្រីពោលគឺគ្រួសារខាងកូនប្រុសបន្ទាប់ពីពេញចិត្ត នឹងកូនក្រមុំណាមួយហើយ តាមបន្ទូល ស្ដេច ជ័យរាមាសួស្ដី មានសេចក្ដីថា :

-បើអ្នកណាចង់ដណ្ដឹងកូនស្រី ដើម្បីកូនប្រុសរបស់ខ្លួន ត្រូវបញ្ជូនស្រី ៣ នាក់ ហៅថា "អ្នកចែចូវ" ឲ្យទៅជួបឪពុក ម្ដាយ ខាងស្រី ៣ ដង ហើយបញ្ជូនស្រី ៣ នាក់ទៀត ហៅថា "អ្នកផ្ទូវ" ដើម្បីដណ្ដឹងកូនស្រីនោះ ។

-ដល់យល់ព្រមហើយគេនាំគ្នា ធីស្លាដក់ស្លាក់ន្សែង ។

ដោយការស្ដីដណ្ដឹង ទាក់ទងនឹងទំនៀមទម្លាប់ខ្មែរ ខ្ញុំសូមលើកយករឿងព្រេង និងពាក្យពេចន៍ខ្លះ ដែលដំណាលតៗ មករហូតដល់សព្វថ្ងៃនេះ ។

<u>ក- រឿងមិត្តសម្លាញ់ពីរនាក់ជាអ្នកឃ្វាលក្របី</u>

មាននិទានថាមានបុរសពីរនាក់ជាអ្នកឃ្វាលក្របីជាមួយគ្នា លុះដល់យូរទៅ ក៏ទៅជាមិត្តសម្លាញ់នឹងគ្នា។ ថ្ងៃមួយអ្នកទាំងពីរបាននិយាយពីគ្រួសាររៀងៗខ្លួន ម្នាក់ថាខ្លួនមានកូនប្រុស ម្នាក់ទៀតថាខ្លួនមានកូនស្រី។ អ្នកមានកូនប្រុសក៏សុំស្នើទៅមិត្រមានកូនស្រីថា ខ្ញុំសុំដណ្ដឹងកូនស្រីរបស់សម្លាញ់មកធ្វើជាកិរិយារបស់កូនប្រុសខ្ញុំ។ មិត្តមានកូនស្រីក៏

សុខចិត្តហើយដើម្បីជាសក្ខីភាពនៃពាក្យស្ដីដណ្ដឹងនេះ មិត្តមានកូនប្រុសក៏ស្រាយ
ថ្នក់សំពត់ យកម្ជូស្លា ហើយនិយាយថា : ដោយយើងនៅក្នុងព្រៃខ្ញុំគ្មានអ្វីក្រៅពីម្ជូស្លានេះ
ដូច្នេះយើងធីស្លានេះទៅដើម្បីសម្រេចការចងស្ពានមេត្រីគ្រួសារយើងទាំងពីរ។
ហេតុនេះហើយ បានជាមានពាក្យថា :

" ស្លាជក់ - ស្លាកន្សែង " ។

<u>ខ- អំពី អ្នកជូរ អ្នកមហា ថង់រង</u>

ចាស់ ៗ លោកថា អ្នកជូរ អ្នកមហា ថង់រង និង អាចារ្យបង្វិលពពិល ធ្វើឡើងតាមការរៀបអាពាហ៍ពិពាហ៍ របស់ ជាលីក្រឹស្នា ដែលជាព្រះរាជបុត្រនៃព្រះបាទស្រីវេស្សន្តរ។

<u>គ-ជ័យហោង-សួស្ដីហោង</u> កាលពីព្រេងនាយនៅប្រទេសកម្ពុជា មានបងប្អូនប្រុសពីរនាក់ ជាអ្នកមានភ័ព្វព្រេងសំណាងដ៏អស្ចារ្យ បងឈ្មោះជ័យ ប្អូនឈ្មោះ សួស្ដី ។ ពេលមួយ ស្ដេចគ្រងរាជ្យ ចូលទិវង្គត ដោយគ្មានបុត្រសម្រាប់សោយរាជ្យជាបន្ត។ ពួកបុរោហិតព្រមទាំងនាហ្មឺនគ្រូបាចារ្យ ក៏សម្រេចផ្សងរកអ្នកមានបុណ្យដោយលែងសត្វដំរីមួយ និង សត្វសេះ មួយ ឲ្យដើររក ។ ដល់ពេលលែងសត្វទាំងពីរនោះទៅសត្វនោះក៏ដើរត្ដោះទៅលំនៅរបស់ ជ័យ និង សួស្ដី។ ពួកបុរោហិតក៏សម្រេចលើកអ្នកទាំងពីរឲ្យជិះលើដំរី ជ័យក៏បានជាស្ដេច ហើយ សួស្ដីជាឧបរាជ ។
នៅពេលអភិសេកស្ដេចថ្មីនេះ ប្រជារាស្ដ្រស្រែកបន្ទឺថា :

ជ័យហោង (ជ័យគឺជ័យជំនះ) គេឆ្លើយថា **ជ័យ**,

សួស្ដីហោង (សួស្ដី គឺ សួស្ដី) គេឆ្លើយថា **សួស្ដី**

មែនហោង (មែនគឺពិតមែន) គេឆ្លើយថា **មែន**,

## <u>២- មង្គលការ</u>

នៅថ្ងៃមង្គលការ កិច្ចសំខាន់ៗដែលធ្វើបន្ដបន្ទាប់គ្នា មាន ដូចជា :

<u>ក- ហែកំណត់</u>

គឺការនាំមកនូវ ជំនូន មាន នំ ផ្លែឈើ ដែលខាងប្រុស យកមកជូនខាងស្រី ។

-ក្បួនហែកំណត់មានអ្នកក្មេងដើរខាងមុខបន្ទាប់មក :
-អាចារ្យ កាន់ស្លាព្រះ
-កូនក្មេងមួយគូកាន់ជើងពានឈើមានគម្រប (ទៀប)
-កូនកំឡោះកាន់ផ្កាស្លា ដោយមានអ្នកកំដរពីរនាក់ ដើរអម
-លោក មហា ខាងប្រុស កាន់ថង់រង
-អ្នកកាន់ ស្លាមាស ស្លាប្រាក់ មួយគូ
-អ្នកកាន់ថាសជំនូន ដើរតាមក្រោយ ជាគូៗ ។
អ្នកដើរជួរមុខស្លៀកពាក់តាមប្រពៃណីខ្មែរ។ នៅផ្ទះខាងស្រីកូនក្រមុំ ដោយមានស្រីកំដរពីរនាក់ នៅចាំទទួលក្បួនហែ ។
លុះក្បួនហែដល់ផ្ទះខាងស្រីហើយ លោកអាចារ្យ សុំ "ផ្លូវដើរ - ជណ្តើរឡើង" ទៅលោកមេបាខាងស្រី ។ បន្ទាប់ ឆ្លើយឆ្លងគ្នា ដោយលេងពាក្យសំដីកំប្លែងខ្លះផង ក្បួនហែក៏បានទទួលការអនុញ្ញាតឲ្យចូលក្នុងផ្ទះ។ លុះយកជំនូនទៅ ដាក់ក្នុងបន្ទប់ទទួលភ្ញៀវហើយ ក៏មានការចរចាគ្នាតាមប្រពៃណីរវាង លោកអាចារ្យ លោកមេបាប្រុស លោកមេបាស្រី។ លោកអាចារ្យមានមុខងារ ជាអាចារ្យផង ជាមហាផង ជាអ្នកផ្លូវផង ។ នៅទីបញ្ចប់កូនកំឡោះនិងកូនក្រមុំ បំពាក់គ្រឿងអលង្ការ គ្នាទៅវិញទៅមក ។
ក្នុងពិធីនីមួយៗ មានលេងភ្លេងកំដរ លុះដល់ចប់ពិធីមានវាយឃ្មោះបន្លឺឡើងមុននឹងចាប់ពិធីមួយទៀតជាបន្ត ។

<u>១- សែនជូនតា</u>

ការសែនជូនតានេះធ្វើឡើងដើម្បីជំរាបដល់មេបាជីដូនជីតាខាងកូនក្រមុំដែលចែកស្ថានទៅហើយ ឲ្យលោកបានជ្រាបពីការមានគ្រួសារនៃកូនក្រមុំ ដែលត្រូវជាសាច់សាលោហិត ហើយសូមឲ្យលោកអញ្ជើញមកត្រេកអរ ប្រសិទ្ធិពរជ័យដល់អនាគត គូស្វាមី ភរិយាទាំងពីរ។ ការនេះជាកិច្ចមួយសំខាន់ណាស់ បើអ្នកណាពុំអាចរៀបមង្គលការឲ្យដល់

ចប់បានទេ គ្រាន់តែបានសែនជូនតា ក៏បាន ដែរ ។ក្នុងការសែននេះមាន នំ ចំណី ផ្លែឈើ ម្ហូបអាហារ សាច់ជ្រូក សាច់មាន់ស្ងោរ ជាដើម ។ ចំពោះ នំ មាន នំអន្សម នំគម នំបត់ នំខ្វៃ នំកង់ខ្សៀន នំឃ្មុស នំសំបុកចាប នំកឹង ។ល។

គ- កាត់សក់

ពិធីកាត់សក់ ជានិមិត្តរូប នៃ ការសំអាតកាយ និង ចិត្ត ឲ្យដល់កូនក្រមុំ កូនកំលោះ ។ កូនកំលោះ អង្គុយខាងស្តាំ កូនក្រមុំ នៅមុខតុមួយ ដែល មានរៀបចំភ្ញីផ្កា ដាក់លំអ និង តាំងវត្ថុផ្សេងៗ ដើម្បីបួងសួង សូមពរជ័យ ពីដូនតា។ ពិធីនេះចាប់ផ្តើមដោយមានទេវតាប្រុសស្រីមួយគូ ចុះមកពីស្ថានទេវលោក (ដើរតួដោយអ្នកលេងភ្លេងការ) យកក្រាសកន្ត្រៃមកលក់ឲ្យលោកមហាសេដ្ឋីដោយបានឮថា លោកមានកូនរៀបមង្គលការ ថ្ងៃនេះ។ បន្ទាប់ពីលោកអាចារ្យ ជាតំណាងលោកសេដ្ឋីបានទិញរបស់ទាំងនោះមក គាត់ក៏ចាប់ផ្តើមកាត់សក់ឲ្យកូន កំលោះ កូនក្រមុំ ។ បន្ទាប់មក ឪពុកម្តាយកូនក្រមុំ កូនកំលោះ បងប្អូន ញាតិមិត្ត ទាំងសងខាង ក៏កាត់សក់ឲ្យអ្នក ទាំងពីរ ជាបន្តៗ ក្នុងបរិយាកាសដ៏សែនរីករាយ។

ឃ- បូតផ្កាស្លា

(ស្លា មានរសចត់ ទំពាផ្សំជាមួយនឹងម្លូបៀក ជាគ្រឿង រម្ងាប់ក្លិនមាត់)

កូនកំលោះ ដើម្បីថ្លែងអំណរគុណដល់ឪពុកម្តាយកូនក្រមុំ ជូន

-ផ្កាស្លា ទី ១ ទៅឪពុកកូនក្រមុំ

-ផ្កាស្លា ទី ២ ទៅម្តាយកូនក្រមុំ

-ផ្កាស្លា ទី ៣ ទៅបងប្រុស (ឬមីងមាកូនក្រមុំ)

ពិធីនេះទាក់ទងនឹងរឿងព្រេងមួយដំណាលថា: កាលណោះមានបុរស៤នាក់ ទៅរៀនវិជ្ជាផ្សេងៗគ្នា។ ម្នាក់រៀនខាងបាញ់ព្រួញ ម្នាក់ខាងទស្សន៍ទាយ ម្នាក់ខាងប្រស់មនុស្សស្លាប់ឲ្យមានជីវិតឡើងវិញ ម្នាក់ទៀតខាងមុជចុះក្នុងទឹក។ ដល់ពេលរៀនចប់កាលណាក៏នាំគ្នាទាំង៤នាក់ វិលមកផ្ទះវិញ។ នៅតាមផ្លូវ មកដល់ព្រៃកមួយ អ្នកចេះទាយនិយាយ ថានៅពេលបន្តិចទៀតនេះ នឹងមានសត្វស្លាប"វាយោកក្ស"មួយពាំយុវតីម្នាក់ដើម្បីយក

ទៅធ្វើជាកិរិយា។ គាប់ជួនពេលជាមួយគ្នានោះ ព្រះរាជបុត្រីព្រះនាមខេមរី នៃព្រះបាទ គ្រាម កំពុងមុជទឹកលេងក្នុងទឹកស្ទឹង ស្រាប់តែមានសត្វស្លាបមួយហើរមក ចក់ពាំយក បាត់ទៅ។លុះសត្វនោះហើរដល់ព្រៃក បុរសដែលចេះបាញ់ក៏យកធ្នូយិតបាញ់ត្រូវ សត្វស្លាបនោះភ្លាម ធ្វើឲ្យព្រះរាជធីតា ធ្លាក់លិចក្នុងទឹក បាត់ទៅ ។

បុរសចេះមុជទឹក ក៏លោតទៅក្នុងទឹក ស្រង់យកនាងនោះមកដាក់លើគោក។ តែនាងនោះ បាត់បង់ជីវិតទៅហើយ។ បុរសចេះប្រស់ ក៏ប្រស់ នាងឲ្យរស់ឡើងវិញបានដូចបំណង។ ដោយឃើញនាងនោះមានរូបឆោមល្អ អ្នកទាំង៤ក៏ចង់បាននាងនោះ ធ្វើជាកិរិយារៀងៗ ខ្លួន។ ដោយដោះស្រាយពុំកើត ក៏យករឿងនេះទៅក្រាបទូលព្រះពោធិសត្វ សូមឲ្យ ព្រះអង្គ ជួយកាត់សេចក្ដី។ ព្រះពោធិសត្វ ក៏មាន បន្ទូលថា :

-នាងនោះត្រូវបានទៅអ្នកស្រង់នាងចេញពីក្នុងទឹកព្រោះថា អ្នកនោះបានប៉ះពាល់ខ្លួន ប្រាណនាង មុនគេ ,

-អ្នកចេះទាយ ត្រូវទុកជាឪពុករបស់នាង

-អ្នកចេះប្រស់ ត្រូវទុកជាម្ដាយរបស់នាង

-អ្នកចេះបាញ់ព្រួញត្រូវទុកជាបងប្រុសរបស់នាង

បន្ទាប់មកព្រះពោធិសត្វបានបញ្ជាឲ្យអ្នកចេះមុជក្នុងទឹក រៀបចំផ្កាស្លា ជាបីថូ,

-ថូធំ មានដោតម្លូ ២១ សន្លឹក និងស្លា ២១ ផ្លែ សម្រាប់ សម្ដែងការដឹងគុណដល់ឪពុក,

-ថូកណ្ដាលមានដោតម្លូ១២សន្លឹកនិងស្លា១២ ផ្លែ សម្រាប់សម្ដែងការដឹងគុណដល់ម្ដាយ,

-ថូតូចមានដោតម្លូ៦សន្លឹក និង ស្លា ៦ផ្លែ សម្រាប់ សម្ដែងការដឹងគុណដល់បងប្រុស ។

មុននឹងជូនផ្កាស្លា ទៅឪពុកម្ដាយ និង បងប្រុស អ្នកភ្លេងច្រៀង(បទកាត់ខាន់ស្លា) បណ្ដាំម្ដាយទៅកូនស្រី ហើយរំលឹកកាលពីម្ដាយពពោះ រួចមកបានទំចិញ្ចឹមបីបាច់ថែរក្សា អប់រំរហូតមកដល់ពេលរៀបអាពាហ៍ពិពាហ៍នេះ ។

<u>ង- បង្វិលពពិល</u>

ពពិលទាំងអស់មាន៣ មួយៗធ្វើអំពីលោហធាតុ មានរាងជាស្លឹកពោធិ៍ហើយនៅចុងស្លឹក ពោធិ៍ គេបិទទៀន ដែលអុជនៅពេលបង្វិលពពិល ។

កូនកំឡោះ ក្រមុំ អង្គុយដូចពេលចងដៃដែរ។ អាចារ្យ ព្រមទាំងគូស្វាមីកិរិយា ៧ គូទៀត អង្គុយនៅជុំវិញ កូន កំឡោះ ក្រមុំ ។ ស្វាមីកិរិយាទាំង៧នេះ សុទ្ធតែជាអ្នកពុំដែល បែកបាក់គ្រួសារ ពោលគឺសុទ្ធតែបានគ្នាជាប្តីប្រពន្ធតាំងពីកំឡោះ ក្រមុំ រហូតមក ។ ការអង្គុយជុំវិញជារង្វង់មូលនេះ ប្រៀបដូចជារបងការពារកុំឲ្យសត្វខ្មោចបិសាច ចូលមកបៀតបៀនដល់កូន កំឡោះ ក្រមុំ បាន ។

លោកអាចារ្យសូត្រធម៌ប្រសិទ្ធិពរ(**ធម៌ជយន្តោ**)ផង ហុចពពិលទៅអ្នកអង្គុយខាងឆ្វេងដៃគាត់ផង មួយម្តងៗ រហូតដល់អស់ពពិលទាំង៣ ។ លុះពពិលធ្វើដំណើរបាន៧ជុំហើយ ទើបគាត់ប្រមូលពពិលទាំង៣នោះមកវិញ កាន់ផ្តោបគ្នា រួចផ្លុំផ្សែងទៀនទៅលើកូនប្រុស កូនស្រី រហូតទាល់តែ ទៀនទាំង៣នោះ រលត់អស់ ។

<u>ដំណើរពពិល ដោយឧកញ៉ាមហាមន្ត្រី ញឹកនូវ</u>

ពពិលទាំង៣ ត្រូវចេញមួយម្តងៗ ពីដៃអាចារ្យ មកអ្នកមហា បន្តៗគ្នាជាលំដាប់ ប្រទក្សិណ ជុំវិញអ្នកសាមីខ្លួន ទាំងពីរ ។

ដំណើរដែលនឹងហុចគ្នា នឹងទទួលគ្នា ត្រូវធ្វើដូចមាន អធិប្បាយ ដូចតទៅនេះ :

- ហុចទៅនឹងដៃឆ្វេង
- ទទួល ត (ទទួលនឹងដៃឆ្វេង)
- ទទួលមកហើយ (កាន់ចំពីមុខ)
- យកដៃស្តាំ មកកាន់ទៀត
- ហើយលើកឲ្យខ្ពស់ឡើង
- ដាក់ ទាប បន្តិច មក
- យកដៃស្តាំបក់អណ្តាតភ្លើងទៀន
- បញ្ចូលក្លិនក្រមួនក្រអូប ទៅឲ្យអ្នកសាមីខ្លួនទាំងពីរ
- រួចទើបហុចតទៅអ្នកខាងឆ្វេងដៃ
- ធ្វើយ៉ាងនេះដរាបលុះតែលោកអាចារ្យឲ្យឈប់។

ច- សំពះផ្ទឹម - ចងដៃ

កូនកំឡោះក្រមុំអង្គុយក្រាបទន្ទឹមគ្នាដៃគងលើខ្នើយទ្រដាវ កូនកំឡោះអង្គុយខាងស្តាំកូនក្រមុំ។ លោកអាចារ្យ ចាប់ផ្តើមយកអំបោះសរសៃសំឡីដែលជ្រលក់ក្នុងទឹកមន្ត មកចងកដៃ កូនកំឡោះក្រមុំ។ បន្ទាប់មកក៏ប្រសិទ្ធិពរជ័យដោយឧទ្ទិសដល់គុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាដើម សូមឲ្យអ្នកទាំងពីរបានជួបតែនឹងសេចក្តីសុខ សេចក្តីចំរើន គ្រប់ប្រការ ។ បន្ទាប់មក ឪពុកម្តាយកូនស្រីកូនប្រុស និង បងប្អូនញាតិមិត្ត ក៏ចូលមកចងដៃអ្នកទាំងពីរ បន្តៗគ្នា ។ នៅពេលនោះ អ្នកភ្លេង លេងបទចងដៃ ។

ឆ- បាចផ្កាស្លា

បន្ទាប់មក លោកអាចារ្យឲ្យសញ្ញាដល់ឪពុកម្តាយញាតិមិត្តទាំងអស់ បាចផ្កាស្លា ទៅលើសាមីខ្លួនទាំងពីរ ។

បន្ទាប់មក ស្វាមីកាន់ស្បៃភរិយា ដើរទក្សិណ ៣ ជុំ ហើយក៏ចូលក្នុងបន្ទប់ផ្សំដំណេក ដោយភ្លេងលេងបទព្រះថោងនាងនាគ ។

ចាប់តាំងពីពេលនេះទៅ អ្នកទាំងពីរជាស្វាមីភរិយាគ្នា ចំពោះភ្នែកអ្នកទាំងពួងក្នុងសង្គម។

## ៣- បន្ទាប់ពីមង្គលការ

បីថ្ងៃក្រោយមកគូស្វាមីភរិយាថ្មីថ្មោងនាំគ្នាទៅវត្ត ដោយមានម៉ែឪគ្រួសារទៅជាមួយផង។

អ្នកទាំងពីរបាននាំចង្ហាន់ទៅប្រគេនព្រះសង្ឃជាចៅអធិការ ឬជាគ្រូធ្លាប់បង្ហាត់បង្រៀនកូនប្រុស ដើម្បីសុំពរជ័យពីព្រះអង្គ ដោយព្រះអង្គបាចផ្កាស្លាឲ្យ ។

**ពាក្យទូន្មាន ដល់ស្វាមី ភរិយា តាម សីលធម៌**

**ស្វាមីត្រូវ** ទំនុកបម្រុង ដោយស្ថានទាំងឡាយ៥យ៉ាង គឺ :

១-ដោយការរាប់អានជាភរិយាពេញទី

២-ដោយមិនមើលងាយ

៣-ដោយមិនប្រព្រឹត្តក្បត់ចិត្ត

៤-ដោយប្រគល់ឲ្យជាធំ (ក្នុងការផ្ទះ)

៥-ដោយការឲ្យគ្រឿងតែងខ្លួន ។

*<u>កិរិយា</u> ដែលស្វាមីទំនុកបម្រុងដោយស្ថានទាំងឡាយ ៥យ៉ាងនេះឯងហើយ រមែងអនុគ្រោះស្វាមីដោយស្ថានទាំងឡាយ ៥យ៉ាងវិញ គឺ :*

*១-ចាត់ចែងការងារដោយល្អ*

*២-សង្គ្រោះជនជាញាតិទាំងពីរខាង ដោយល្អ*

*៣-មិនប្រព្រឹត្តក្បត់ចិត្ត*

*៤-ថែទាំទ្រព្យដែលស្វាមីរកបានមក*

*៥-ឈ្លាសមិនខ្ជិលច្រអូសក្នុងកិច្ចការសព្វគ្រប់ ។*

*<u>សេចក្តីបន្ថែមលើអត្ថបទ“មង្គលការ”</u>*

*នៅពេលបង្ខិលពពិល លោកអាចារ្យ ច្រើននាំសូត្រធម៌ ប្រសិទ្ធិពរ* ***ជយន្តោ***... *ដូចតទៅនេះ ៖*

**ជយន្តោ ពោធិយា មូលេ សក្យានំ នន្ទិវឌ្ឍនោ ឯវំ ត្វំ វិជយោ ហោហិ ជយស្សុ ជយមង្គលេ អបរាជិតបល្លង្កេ សីសេ បឋវិបោក្ខរេ អភិសេកេ សព្វពុទ្ធានំ អគ្គប្បត្តោ បមោទតិ**

*-ព្រះសម្មាសម្ពុទ្ធទ្រង់ញុំាងសេចក្តី ត្រេកអរនៃសក្យ:ទាំងឡាយឲ្យចម្រើន ព្រះអង្គទ្រង់ឈ្នះមារ ហើយបានដល់នូវភាពជាបុគ្គលប្រសើរបំផុតទ្រង់រីករាយ (ចំពោះធម៌ដែលព្រះអង្គត្រាស់ដឹង)លើអបរាជិតបល្ល័ង្កជាជយមង្គលទៀបគល់ពោធិព្រឹក្សត្រង់ផ្ចិតផែនដីដូចជាស្លឹកឈូក ជាទីអភិសេកនៃព្រះពុទ្ធគ្រប់ព្រះអង្គ(យ៉ាងណាមិញ) សូមឲ្យអ្នកជាបុគ្គលមានជំនះឈ្នះមារ(អស់សត្រូវ)យ៉ាងនោះឯង,*

**-សុនក្ខត្តំ សុមង្គលំ សុបភាតំ សុហុដ្ឋិតំ សុខណោ សុមុហុត្តោ ច សុយិដ្ឋំ ព្រហ្មចារិសុ,** *-ពេលណាដែលសត្វទាំងឡាយ ប្រព្រឹត្តល្អដោយ កាយ វាចា ចិត្ត ពេលនោះឈ្មោះថាជានក្ខត្តប្ញក្សល្អជាមង្គលល្អ ជាពេលភ្លឺស្វាងល្អ ជាពេលនៃអរុណរះល្អ ជាខណ:ល្អ ជាយាមល្អ ទានដែលបុគ្គលបានបូជាហើយដល់ព្រហ្មចារីបុគ្គលទាំងឡាយក្នុងពេលនោះ ឈ្មោះថា ជាគ្រឿងបូជាល្អ,*

**-បនក្ខិណំ កាយកម្មំ វាចាកម្មំ បនក្ខិណំ បនក្ខិណំ មនោកម្មំ បណិធីតេ បនក្ខិណា,**
-(ក្នុងថ្ងៃនោះ)កាយកម្មក៏ឈ្មោះថានាំឲ្យមានសេចក្តីចំរើន វចីកម្មក៏ឈ្មោះថានាំឲ្យមាន សេចក្តីចំរើន មនោកម្មក៏ឈ្មោះថានាំឲ្យមានសេចក្តីចំរើន សេចក្តីប្រាថ្នាទាំងឡាយ របស់អ្នកទាំងនោះ ក៏ឈ្មោះថានាំឲ្យមានសេចក្តីចំរើន,

**-បនក្ខិណានិ កត្វាន លភន្តត្ថេ បនក្ខិណោ,** -បុគ្គលដែលបានធ្វើនូវ កាយកម្ម វចីកម្ម មនោកម មគួរដល់សេចក្តីចំរើនយ៉ាងនេះហើយក៏រមែងបាននូវប្រយោជន៍ដ៏ចំរើនទាំងឡាយ ។ល។

## ៨-១-៨ បុណ្យជូនកុសលដល់មនុស្សឈឺ ឬ មនុស្សស្លាប់

### ១-មនុស្សឈឺ

នៅប្រទេសខ្មែរយើង កាលណានៅក្នុងគ្រួសារ មាន មនុស្សចាស់ ឈឺ ដូចជាឪពុក ម្តាយជាដើមកូនចៅច្រើននិយមធ្វើបុណ្យ ដោយនិមន្តព្រះសង្ឃមកឯផ្ទះដើម្បីប្រទានសីល ដល់អ្នកជម្ងឺ និង ទទួលចង្ហាន់ សង្ឃទាន ។ ជូនកាលគេធ្វើសង្ឃទាន ចំនួន ៣ ថ្ងៃ ឬ ៧ ថ្ងៃជាប់គ្នា ទៅតាមធនធានដែលអាចធ្វើបាន ។ ដោយបុណ្យកុសលជួយ អ្នកជម្ងឺខ្លះ ជាសះស្បើយក៏មាន បើមិនជាទេ ក៏យើងបានធ្វើ បុណ្យជូនគាត់ ទាន់គាត់នៅរស់ដែរ ។

បើអ្នកជម្ងឺនៅមន្ទីរពេទ្យគេអាចនិមន្តព្រះសង្ឃមកទទួលចង្ហាន់បានដែរ ស្រេចតែយើង ទាក់ទងខាងមន្ទីរពេទ្យ។

បើអ្នកជម្ងឺនៅផ្ទះគេមាននិមន្តព្រះបដ តាំងតាមជញ្ជាំង និងតាំងនៅតាមពិតានផ្ទះ ដើម្បីឲ្យអ្នកជម្ងឺឃើញព្រះពុទ្ធរូប ជាហេតុធ្វើឲ្យអារម្មណ៍គាត់ មូលនៅក្នុងកុសល តែម្យ៉ាង។

ពេលល្ងាចគេនិមន្តព្រះសង្ឃស្មូត្រធម៌រឿងគិរីមានន្ទ (រឿងសញ្ញា១០ប្រការ) ព្រោះកាល សម័យព្រះពុទ្ធ មានភិក្ខុ មួយអង្គ ព្រះនាមគិរីមានន្ទ លោកមានអាពាធ លុះ ព្រះអានន្ទ លោកស្មូត្រធម៌នេះទៅ ព្រះគិរីមានន្ទ លោកក៏បានជាសះស្បើយ ។

ក្រៅពីនេះ ព្រះសង្ឃ លោកស្មូត្រធម៌ ៖

អនិច្ចំ ទុក្ខំ អនត្តា ដូចជាអនត្តលក្ខណសូត្រ។ នៅក្នុងគម្ពីរមានដំណាលថា សូត្រសតិប្បដ្ឋាន ក៏មាន សូត្រពោជ្ឈង្គ ក៏មាន ប៉ុន្តែ គ្រឹះធំ គឺ គិរីមានន្ទសូត្រ ។ បន្ទាប់ពីព្រះសង្ឃសូត្ររួចទៅ គេអាចអញ្ជើញចាស់ទុំនៅក្នុងភូមិឲ្យមកសូត្រធម៌ និយាយ អំពីគុណបារមី ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ហៅធម៌ **ការជា** មិនមែនធម៌ អភិធម្ម ទេ ។

បើនៅមន្ទីរពេទ្យគេពុំអាចធ្វើបានដូចនៅផ្ទះទេព្រោះខ្លាចរំខានដល់អ្នកជិតខាងតែជួនកាល គេអាចចាក់កាសែត(K7) ធម៌គិរីមានន្ទសូត្រ ជូនគាត់ស្តាប់បានដែរ ដោយបើកសំឡេង តិចៗ ។ បើអាចធ្វើបាន គេនាំគាត់ខមាទោស ព្រះរតនត្រ័យ ថ្វាយខ្លួនសាជាថ្មី គឺថា សម្រិតសម្រាំងអំពីសីល អំពីត្រៃសរណគមន៍ ឲ្យបានស្អាត ព្រោះថា សេចក្តីស្លាប់ មិនទៀង។

ប៉ុន្តែយើងធ្វើមើលមនុស្សដែរ បើជាមនុស្សធ្លាប់ ប្រតិបត្តិធម៌ យកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងនោះ បើយើងធ្វើតាមរបៀបខាងលើនេះ គាត់នឹងសប្បាយចិត្ត តែបើគ្រាន់តែជាមនុស្សកាន់ព្រះពុទ្ធសាសនាតាមតែទំនៀមទម្លាប់ទេនោះ បើគាត់នៅដឹង មានសតិស្មារតីនៅឡើយ យើងគ្រាន់តែពន្យល់ធម៌គាត់កុំឲ្យគាត់ជាប់ជំពាក់ចិត្តនឹង ទ្រព្យ សម្បត្តិកូនចៅព្រោះដល់ពេលនេះហើយ គាត់ជួយអ្វីថែមទៀតលែងបានហើយ តែ គប្បីនឹកគិតតែ សេចក្តីល្អ អំពើល្អ ដែលធ្លាប់បានធ្វើ នឹកដល់គុណ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដែលលោកបានបង្ហាញផ្លូវដើរទៅរកសេចក្តីសុខ ស្ងប់ អស់តណ្ហា ឧបាទាន ។ ធ្វើបុណ្យជូនគាត់នៅពេលគាត់ដឹង មានស្មារតីនៅឡើយ នាំឲ្យចិត្តគាត់ ជ្រះថ្លា ប្រសើរជាងពេលដែលគាត់លែងដឹងខ្លួន ។

## <u>២ លុះគាត់ស្លាប់ហើយ</u>

ខាងព្រះពុទ្ធសាសនាមិនមានកិច្ចអ្វីប្រញាប់ប្រញាល់ពេក ក័យពេកនោះទេ ព្រោះ គាត់ឈឺ យើងក៏ដឹងជាមុនរួចទៅហើយ បើមិនបាននិមន្តលោកទៅសូត្រមន្តភ្លាមនោះក៏ អត់ខុសឆ្គងអ្វីដែរ ធ្វើតែទៅតាមសម្រួលហូរហែទៅ ។

កិច្ចដែលគួរធ្វើគឺ ៖

បើស្លាប់នៅមន្ទីរពេទ្យយើងនិមន្តព្រះសង្ឃទៅបង្សុកូលមួយជង ឬច្រើនដងតាមលទ្ធភាព ។ ការនិមន្តបង្សុកូលនេះមិនមែនជាកិច្ចបន្ទាន់ពេកទេ ។ ជាមួយគ្នានោះ នៅផ្ទះបើយើងមានលទ្ធភាព យើងអាចនិមន្តព្រះសង្ឃធ្វើបុណ្យសង្ឃទានរាល់ៗថ្ងៃ ឬមួយនៅវត្តយើងអាចចូលលុយនឹងយាយៗ ធ្វើចង្ហាន់លោករាល់ថ្ងៃ ហើយទូលព្រះសង្ឃឲ្យជួយឧទ្ទិសកុសលទៅដល់អ្នកដែលស្លាប់នោះក៏បាន ។

-លុះដល់ថ្ងៃបូជា ឬ បញ្ចុះសព គេគប្បីនិមន្តព្រះសង្ឃឲ្យមកដល់កន្លែងតម្កល់សពមុនពេលដែលគេដង្ហែសពចេញទៅ ដើម្បីសូត្រធម៌បង្សុកូលតាមប្រពៃណី។ បន្ទាប់ពីបង្សុកូលរួចហើយ ព្រះសង្ឃខ្លះក៏គង់ក្នុងរថយន្តដឹកសព ដង្ហែជាមួយនឹងកូនឬចៅម្នាក់កាន់រូបថតសព។

<u>៣- នៅឈាបនដ្ឋាន</u>

លុះគេយកក្តារមឈូសសពមកដល់ហើយត្រូវរៀបចំកន្លែងតាំងព្រះពុទ្ធរូប ដោយមានជើងទៀនពីរគូ និងប្រដាប់សំរាប់ដោតធូប២ (មួយនៅមុខព្រះពុទ្ធរូប មួយទៀតនៅមុខក្តារមឈូសសព) ។

ការចាប់ផ្តើមពិធីមានគោលៗដូចតទៅនេះ ៖

១-ថ្វាយបង្គំព្រះ

២ -សមាទាននិច្ចសីល

៣-សុន្ទរកថា អំពីជីវប្រវត្តិ សព

៤-ការថ្លែងអំណរគុណពីកូនចៅដល់ភ្ញៀវ (បើខ្វះពេល ត្រូវធ្វើនៅពេលជាបន្ទាប់ក៏បាន)

៥-ព្រះសង្ឃសូត្រធម៌បង្សុកូល

៦-អញ្ជើញភ្ញៀវដាក់ផ្កា គោរពសព ខមាទោសសព

៧-គេរំកិលសព យកទៅបូជា

៨-សុន្ទរកថា របស់ភ្ញៀវ ឬ មិត្តភក្តិ (បើមាន)

៩-កូនចៅថ្លែងអំណរគុណដល់ភ្ញៀវ (បើពុំទាន់ធ្វើ)

១០-និមន្តព្រះសង្ឃសម្តែងធម្មទេសនា(បើមាន)
១១-ចប់ពិធី ព្រះសង្ឃនិងភ្ញៀវត្រឡប់ទៅផ្ទះ ។
១២-កូនចៅនៅចាំទទួលធាតុ ។

<u>សង្កេត</u>

ឱកាសអញ្ជើញសពទៅបូជា បើចង់បានឆ្អឹងខ្លះត្រូវប្រាប់ទៅបុគ្គលិកធ្វើការបូជា ជាមុន។

## <u>៤- ដល់គ្រប់ ៧ថ្ងៃ ១០០ថ្ងៃ ឬ ខួបប្រចាំឆ្នាំ</u>

គេអាចធ្វើបុណ្យនៅវត្តក៏បាន នៅផ្ទះក៏បាន ឬមួយយកម្ហូបមកវត្ត តែមួយស្រាក់ក៏បានដែរ មិនមានអ្វីជាកំណត់ទេ ។

នៅស្រុកបារាំងបើគេធ្វើបុណ្យ គេច្រើនរើសយកថ្ងៃសៅរ៍ ឬថ្ងៃអាទិត្យ ទោះថ្ងៃនោះមិនចំថ្ងៃខួបក៏ដោយ ក៏មិនអីដែរ នេះដើម្បីឲ្យមិត្តភក្តិ បងប្អូនដែលជាប់ការងារ មានឱកាសមកចូលរួមផង ។

អ្នកខ្លះ គេរំលង បុណ្យ៧ថ្ងៃ គេធ្វើនៅផ្ទះ ហើយចាំដល់បុណ្យខួប១០០ថ្ងៃ ទើបគេធ្វើនៅវត្តដោយជំរាបមិត្តភក្តិថា បុណ្យខួប ១០០ ថ្ងៃ។

គម្ពីរព្រះពុទ្ធសាសនាបង្រៀនតែឲ្យកូនចៅចេះដឹងគុណគាត់ ថែទាំគាត់ឲ្យល្អកាលគាត់នៅរស់ តែយើងត្រូវតែធ្វើដើម្បីបានកុសលផលបុណ្យ ទៅគាត់ផង និងមកដល់យើងផង។

កាលណាគាត់ស្លាប់បានមួយឆ្នាំហើយ កូនចៅគេធ្វើបុណ្យខួប។ របៀបធ្វើបុណ្យគេធ្វើធំក៏បាន តូចក៏បាន ដូចជំរាបមកខាងលើរួចហើយ ហើយចាប់តាំងពីមួយឆ្នាំឡើងទៅគេធ្វើបុណ្យខួបនេះ រាល់ ៗ ឆ្នាំ ។៚

## ៨-២ បុណ្យពុទ្ធសាសនា

បុណ្យពុទ្ធសាសនាដែលគេរាប់ថាជាបុណ្យប្រចាំឆ្នាំគឺៈ បុណ្យមាឃបូជា បុណ្យវិសាខបូជា បុណ្យចូលវស្សា បុណ្យចេញវស្សា និង បុណ្យកឋិន ។

បុណ្យចូលឆ្នាំ និង បុណ្យភ្ជុំបិណ្ឌ ជាបុណ្យជាតិ ភ្ជាប់នឹង សាសនា ។

### ៨-២-១ បុណ្យមាឃបូជា

បុណ្យមាឃបូជាគេធ្វើនៅថ្ងៃពេញបូណ៌មីខែមាឃ ដើម្បីរំលឹកនូវការជួបជុំនៃព្រះសង្ឃដ៏ច្រើនៗ បុណ្យនេះ ប្រកប ដោយអង្គ ៤ (ហៅថា ចតុរង្គសន្និបាត) គឺ ៖

១-ថ្ងៃពេញបូណ៌មីខែមាឃ

២-ព្រះសង្ឃចំនួន១២៥០អង្គ បានមកជួបជុំគ្នាដោយមិនមាននរណានិមន្ត ឬ បានណាត់គ្នាទុកជាមុនទេ

៣-ព្រះសង្ឃទាំង១២៥០អង្គនេះសុទ្ធតែជាឯហិភិក្ខុគឺបានបួសដោយវិធីដែលព្រះពុទ្ធលោកគ្រាន់តែថា"**ឯហិភិក្ខុ អ្នកចូរមកជាភិក្ខុចុះ**" ប៉ុណ្ណោះក៏ជាការស្រេច មិនបាច់មានគ្រូសូត្រទេ

៤- ព្រះសង្ឃចំនួន ១២៥០ អង្គនេះ សុទ្ធតែជាព្រះខីណាស្រព គឺអស់កិលេស បានសម្រេចអរហត្តផល និង មានឫទ្ធានុភាពច្រើន ។

ចតុរង្គសន្និបាតនោះកើតឡើងក្នុងវត្តវេឡុវ័នក្រុងរាជគ្រឹះក្រោយពេលដែលព្រះពុទ្ធបានត្រាស់ដឹងហើយ៩ខែ។ សន្និបាតបែបនោះមានតែម្តងប៉ុណ្ណោះ ក្នុងសន្និបាតនោះព្រះពុទ្ធបានបំពេញកិច្ច២គឺ សម្តែងឱវាទបាតិមោក្ខ និង តែងតាំងព្រះអគ្គសាវក ។

<u>ក-ឱវាទបាតិមោក្ខ</u> មានគោល ៣ គឺ ៖

១-ការឈប់ធ្វើអំពើអាក្រក់គ្រប់យ៉ាង

២-ការខំធ្វើអំពើល្អឲ្យច្រើនឡើង ៗ

៣-ការសំអាតចិត្តរបស់ខ្លួនឲ្យស្អាតផូរផង់ ។

នេះជាសេចក្តីសង្ខេបនៃពាក្យ ប្រៀនប្រដៅរបស់ ព្រះពុទ្ធ ។ល។

<u>ខ-ការតែងតាំងអគ្គសាវក</u>

១-ព្រះសារីបុត្រដែលមានបញ្ញាច្រើនជាអគ្គសាវកស្តាំ

២-ព្រះមោគ្គល្លានដែលមានឫទ្ធិច្រើន ជាអគ្គសាវកឆ្វេង
ក្រៅពីនេះ គឺនៅថ្ងៃពេញបូណ៌មីខែមាឃនេះដែរ តែឆ្នាំខុសគ្នា មានហេតុការណ៍មួយទៀត គឺការដាក់បង់នូវអាយុសង្ខារ កំណត់ថ្ងៃចូលបរិនិព្វានៗ
ព្រះដ៏ទ្រង់ញាណបានសម្រេចថា :
"អំណឹះពីនេះទៅតែ ៣ ខែទៀតទេ តថាគត នឹងបរិនិព្វាន ហើយ" ។
មាឃបូជាគេធ្វើដើម្បីរំលឹកនូវហេតុការណ៍ ដូចបានជម្រាបមកខាងលើនេះ ។

## ៨-២-២ បុណ្យវិសាខបូជា

បុណ្យវិសាខបូជាគេធ្វើនូវថ្ងៃពេញបូណ៌មីខែវិសាខ ដើម្បីរំលឹក
**ថ្ងៃប្រសូត ថ្ងៃត្រាស់ដឹង** និង **ថ្ងៃបរិនិព្វាន** នៃ ព្រះសម្មាសម្ពុទ្ធ ។
ថ្ងៃប្រសូត :
ព្រះអង្គប្រសូតថ្ងៃសុក្រ ពេញបូណ៌មីខែវិសាខ ឆ្នាំច មុនព.ស. ៨០ ឆ្នាំ ។
ថ្ងៃត្រាស់ដឹង: ព្រះអង្គត្រាស់ដឹងថ្ងៃពុធពេញបូណ៌មីខែវិសាខឆ្នាំរកា មុន ព.ស.៤៥ ឆ្នាំ ។
ថ្ងៃបរិនិព្វាន :
ព្រះអង្គចូលបរិនិព្វានថ្ងៃអង្គារពេញបូណ៌មីខែវិសាខឆ្នាំម្សាញ់ដែលទុកជាថ្ងៃចាប់ផ្តើមនៃពុទ្ធសករាជហើយគេកំណត់យក ថ្ងៃ១រោចខែវិសាខ ឆ្នាំម្សាញ់នោះ ជាថ្ងៃទី ១ នៃពុទ្ធសករាជ ។

ប្រសូតក៏ថ្ងៃពេញបូណ៌មីខែពិសាខ ត្រាស់ដឹងក៏ថ្ងៃពេញបូណ៌មី បរិនិព្វានក៏ថ្ងៃពេញបូណ៌មី ដូចនេះ ពេញបូណ៌មី មានន័យ សំខាន់ណាស់ ចាស់ៗលោកជំណាលថា :
"ធ្វើបុណ្យ១ដង បានផលដល់ទៅ៣ដង ។ បណ្តាថ្ងៃទាំង៣ ថ្ងៃត្រាស់ដឹងសំខាន់ណាស់ ព្រោះព្រះពុទ្ធបាននាំមកនូវពន្លឺដ៏មហាស្ចារ្យដល់សត្វលោក ដែលមិនអាចរកសាស្តាណាមកប្រៀបផ្ទឹមបាន ។

ហេតុនេះហើយបានជា នៅថ្ងៃដ៏សំខាន់នេះ ពីដើមមក គេធ្វើបុណ្យគគ្រឹកគគ្រេង មិនដូចឥឡូវនេះទេ ដែលដូចជា សោះកក្រោះពេកណាស់ ។ យើងគួរតែប្រជាប់គ្រប់ផ្ទះ សម្បែងដោយទង់ជាតិ ទង់សាសនា រៀបក្តីផ្កា ប្រទីបជ្វាលា បូជាព្រះរតនត្រ័យ ឲ្យបានល្អ ។

ចំណែកនៅវត្តអារាមគួរនាំគ្នា ធ្វើបុណ្យវិសាខបូជា ឲ្យកើតសទ្ធាជ្រះថ្លាមានបញ្ញាភ្លឺស្វាង យ៉ាងច្បាស់លាស់លើសថ្ងៃបុណ្យឯទៀត។ ដើម្បីបូជាចំពោះព្រះពុទ្ធបរមគ្រូយើង រាល់បុណ្យវិសាខបូជា ក្នុង១ឆ្នាំម្តង សម្តេចសង្ឃគួរតែដឹកនាំគ្នាប្រមូលបច្ច័យរួមគ្នាកសាងជាសាលារៀន ១ខ្នងឬ អ្វីមួយ ទុកជាទីរលឹក រៀងរាល់ឆ្នាំ ។

## ៨-២-៣ បុណ្យចូលវស្សា

សម័យនោះព្រះពុទ្ធមានព្រះភាគទ្រង់គង់នៅវត្តវេឡុវ័ន ទៀបក្រុងរាជគ្រឹះ។ គ្រានោះឯងការនៅចាំវស្សា ព្រះមានព្រះភាគមិនទាន់បានបញ្ញត្តដល់ភិក្ខុទាំងឡាយនៅឡើយ។ ភិក្ខុទាំងឡាយ ក៏ត្រាច់ទៅមកគ្រប់រដូវ ដូចជាវស្សានរដូវជាដើម ដែលជារដូវភ្លៀង។ មនុស្សទាំងឡាយក៏ពោលបន្ទុះបង្អាប់ថា ពួកសមណៈជាសក្យបុត្តិយ៍ មិនសមបើនឹងដើរជាន់ស្មៅស្រស់ទាំងឡាយ បៀតបៀននូវវត្ថុដែលមានជីវិត ញ៉ាំងសត្វតូចៗជាច្រើនឲ្យដល់នូវសេចក្តីវិនាសសោះ សូម្បីពួកបរិព្វាជក មានលទ្ធិដទៃ ជាអ្នកពោលនូវធម៌អាក្រក់ម្តេចគង់នឹងសម្ងំឈប់សម្រាកនៅចាំវស្សា សូម្បីពួកសត្វស្លាបនេះទៀតសោតក៏គង់ធ្វើសំបុកលើចុងឈើទាំងឡាយហើយសម្ងំឈប់សម្រាកនៅចាំវស្សាដែរ។ ចំឡែកតែពួកសមណៈជាសក្យបុត្តិយ៍នេះនៅតែដើរត្រាច់ទៅត្រាច់មក។ កាលមនុស្សទាំងនោះកំពុងពោលទោសតិះដៀលបន្ទុះបង្អាប់ ភិក្ខុទាំងឡាយក៏បានឮច្បាស់ហើយនាំសេចក្តីនេះទៅក្រាបទូលព្រះដ៏មានព្រះភាគ។ ក្នុងពេលនោះព្រះមានព្រះភាគ ក៏ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមក ហើយមានបន្ទូលថា: “ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតឲ្យភិក្ខុចូលវស្សា (នៅចាំវស្សា)” ឯរយៈពេលចូលវស្សា ចំនួន ៣ ខែ គឺចាប់ពីថ្ងៃ ១ រោច ខែអាសាឍដល់ថ្ងៃពេញបូណ៌មីខែអស្សុជ។
បើមានខែអាសាឍ២ដងត្រូវចាប់ថ្ងៃ១រោចខែអាសាឍក្រោយ(ទុតិយាសាឍ)។

ក្នុងពេលចូលវស្សាភិក្ខុសង្ឃមិនអាចទៅស្នាក់នៅទីដទៃ(ក្រៅពីកន្លែងខ្លួន)បានទេ។ ភិក្ខុណាប្រព្រឹត្តកន្លង ភិក្ខុនោះឈ្មោះថាមានវស្សាដាច ត្រូវមានទោស(អាបត្តិ) ប៉ុន្តែបើមានកិច្ចសំខាន់ដូចជាមានគេនិមន្តទៅធ្វើបុណ្យជាដើម អាចនិមន្តទៅបានដោយវិធីលើកសត្តាហករណីយ អស់រយៈពេលយ៉ាងយូរបំផុតត្រឹម៧ថ្ងៃ។ ភិក្ខុអ្នកនៅចាំវស្សាមិនដាច់អស់រយៈពេល ៣ ខែ (ត្រៃមាស) ត្រូវបានអានិសង្សចាំវស្សានិង មានសិទ្ធិទទួលកឋិនបានទៀត។ តាមធម្មតា បុណ្យចូលវស្សា ពុទ្ធបរិស័ទតែងតែយកសំពត់ស្រង់ទឹកភ្លៀង (វស្សិកសាដិកា) ទៅប្រគេនព្រះសង្ឃព្រោះព្រះពុទ្ធអង្គបានអនុញ្ញាតឲ្យភិក្ខុស្វែងរកទុកប្រើប្រាស់តាំងពីមុនពេលចូលវស្សា១ខែម៉្លេះ។ លើសពីនេះទៀត នៅវត្តពីបុរាណកាលមានបវារណាបើកឱកាស ជួយសម្រួលដល់ភិក្ខុសង្ឃដែលមានការខ្វះខាតនូវបច្ច័យ៤។

## ៨-២-៤ បុណ្យចេញវស្សា

បុណ្យចេញវស្សា ជាបុណ្យដែលព្រះសង្ឃចូលវស្សាអស់ចំនួន៣ខែ ហើយត្រូវចេញវិញ។ បុណ្យនេះប្រារព្ធឡើងនៅថ្ងៃ១៥កើតខែអស្សុជ(ខែតុលា-វិច្ឆិកា)។

តាមទំនៀមនៅពេលបុណ្យចេញវស្សា អ្នកស្រុកគេយកសំពត់ចំណាំវស្សា(ស្បង់) ទៅប្រគេនព្រះសង្ឃមុននឹងលោកចេញដំណើរទៅកាន់ទីផ្សេងៗទៀត។ តែឥឡូវនេះអ្នកស្រុកពុំសូវធ្វើទេ ព្រោះបុណ្យនេះជាប់នឹងបុណ្យកឋិន។ ម្យ៉ាងទៀតតាមគម្ពីរដំណាលថា នៅសម័យពុទ្ធកាលដល់វស្សាទី៧ព្រះពុទ្ធអង្គបានយាងទៅកាន់ស្ថានតាវត្តឹង្សដើម្បីប្រោសព្រះមាតាហើយនៅថ្ងៃចេញវស្សានោះទើបព្រះអង្គលោកយាង វិលត្រឡប់មកវិញតាមជណ្តើរកែវនៅត្រង់“សង្កស្សនគរ” នៃប្រទេសឥណ្ឌាសព្វថ្ងៃនេះ។ ហើយនៅពេលនោះព្រះអង្គបានធ្វើ យមកបាដិហារិយ៍ បើកលោកឲ្យពពួកទេវតានិងមនុស្សទាំងឡាយមើលឃើញគ្នាទៅវិញទៅមក។

<u>សេចក្តីសង្កេត</u> :

ថ្ងៃចេញវស្សាជាថ្ងៃសំខាន់បើអាចធ្វើបានគួរតែបបួលគ្នាមកវត្តឲ្យបានច្រើនដើម្បីធ្វើបុណ្យធ្វើទាន នៅថ្ងៃមហាបវារណានេះ ។

## ៨-២-៥ បុណ្យកឋិន

បុណ្យកឋិន ធ្វើឡើងដើម្បីប្រគេនស្បង់ ចីវរ ឬ សង្ឃាដី (ត្រៃចីវរ) ដល់ព្រះសង្ឃដែលគង់នៅចាំវស្សាអស់ត្រីមាស នៅក្នុងវត្តអារាម ។ បុណ្យកឋិនមានតាំងពីពុទ្ធកាលម៉្លេះ បុណ្យនេះគេប្រារព្ធចាប់ពីថ្ងៃ១រោចខែអស្សុជ ទៅដល់ថ្ងៃ១៥កើតខែកត្តិក។

ក្នុងរយៈ២៩ថ្ងៃនេះ គេអាចធ្វើបុណ្យកឋិននៅថ្ងៃណាមួយក៏បានដែរ។ តែបុណ្យនេះប្លែកពីបុណ្យទាំងពួងដោយហេតុ៥យ៉ាង ដូចតទៅនេះ គឺ ៖

១-ប្លែកដោយកាល គឺមិនអាចធ្វើរាល់ថ្ងៃបានទេ។ មួយឆ្នាំ ធ្វើបានតែរវាង ២៩ ថ្ងៃ តាំងពី ១រោចខែអស្សុជ ទៅទល់នឹងថ្ងៃពេញបូណ៌មីខែកត្តិក ប៉ុណ្ណោះ ។ ហើយមួយវត្តបានតែម្តង ក្នុង១ឆ្នាំ ។

២-ប្លែកដោយវត្ថុគឺសំពត់ដែលជាកឋិនវត្ថុបានតែស្បង់ឬចីពរឬសង្ឃាដី ហើយចំពោះវត្ថុ៣មុខនេះព្រះសង្ឃអ្នកក្រាលគ្រង លោករើសយកវត្ថុណាមួយ ក្រាលគ្រង់ក៏បានស្រេចលើព្រះទ័យលោក ឲ្យតែវត្ថុនោះៗត្រឹមត្រូវតាមវិនយប្បញ្ញត្តិ ។

៣-ប្លែកដោយអំពើគឺបុគ្គលអ្នកធ្វើគប្បីធ្វើឲ្យត្រឹមត្រូវតាមវិនយប្បញ្ញត្តិ ហើយព្រះសង្ឃគប្បីក្រាលគ្រងឲ្យត្រឹមត្រូវតាមវិនយប្បញ្ញត្តិដែរទើបកើតជាកឋិនត្រឹមត្រូវបានអានិសង្ស ។

៤-ប្លែកដោយអានិសង្សគឺបុគ្គលអ្នកធ្វើក៏បានអានិសង្សព្រះសង្ឃអ្នកទទួលក្រាលគ្រងនិងអនុមោទនាក៏បានអានិសង្ស៥យ៉ាងដូចមានចែងក្នុងវិន័យបិដកត្រង់កឋិនក្ខន្ធកៈនោះសព្វគ្រប់ស្រាប់ហើយ។

៥-ប្លែកដោយបដិគ្គាហកៈ(អ្នកទទួល)គឺបានតែភិក្ខុ ក្រៅពីនេះពុំបានហើយភិក្ខុសោតទៀត លុះណាតែបាននៅចាំវស្សាអស់ ៣ខែ ទើបបាន ។

សូមជម្រាបថាដើមឡើយ ក្នុងបឋមពោធិកាល ភិក្ខុប្រើប្រាស់តែ **បង្សុកូលចីវរ** ពុំទាន់ឲ្យប្រើ**គហបតីចីវរ** នៅឡើយទេ។

សម័យមួយ កាលព្រះសម្មាសម្ពុទ្ធគង់នៅចាំវស្សានាវត្តជេតពន ជិតដល់ថ្ងៃចូល

វស្សាហើយ ភិក្ខុ៣០អង្គនៅស្រុកបាវ៉ា ប្រាថ្នានឹងចង់ទៅថ្វាយបង្គំព្រះដ៏មានព្រះភាគ មុនថ្ងៃចូលវស្សា តែទៅមិនទាន់ ក៏ចូលវស្សានៅជនបទមួយ ត្រង់កណ្តាលផ្លូវ។ លុះបវារណាចេញវស្សាហើយ ទើបនាំគ្នាទៅថ្វាយបង្គំព្រះអង្គ។ ពេលដែលភិក្ខុទៅនោះភ្លៀងច្រើនពេក ភិក្ខុទាំងនោះមានស្បង់ចីវរទទឹកជោកដោយទឹកភ្លៀង ហើយដោយហេតុចង់ឃើញព្រះភក្ត្រព្រះអង្គឆាប់ៗ ក៏នាំគ្នាចូលទៅថ្វាយបង្គំទាំងស្បង់ចីពរទទឹកនោះ។ ព្រះអង្គទតឃើញដូច្នោះក៏ទ្រង់អនុញ្ញាតឲ្យភិក្ខុព្រះពុទ្ធសាសនាទទួលសំពត់កឋិនបានតាំងពីពេលនោះមក។

កិច្ចបុណ្យកឋិនដែលខ្មែរយើងតែងធ្វើជាប់ជាប្រពៃណីតាំងពីបុរាណកាល មាន ៨ ថ្នាក់ ៖

១-កិច្ចធ្វើសំពត់កឋិន

២-កិច្ចសុំវត្តធ្វើកឋិន

៣-កិច្ចផ្សាយដំណឹងបុណ្យកឋិន

៤-កិច្ចសូត្រមន្តកឋិន និង ទេសនា

៥-កិច្ចហែកឋិនប្រទក្សិណព្រះវិហារ (វិលស្តាំ)៣ជុំ

៦-កិច្ចសូត្រសុទ្ធរកថា ពណ៌នា ពីបុណ្យកឋិន

៧-កិច្ចវេរសំពត់កឋិននិងបរិក្ខារជាបរិវារកឋិនដោយមានអាចារ្យជាអ្នកនាំមុខ

៨-កិច្ចឧទ្ទិសផលរបស់ឧបាសក (យំ កិញ្ចិ... )

(ចប់បុណ្យកឋិន)

<u>សម្គាល់</u> :

បន្ទាប់ពីកិច្ចឧទ្ទិសផលរួចហើយព្រះសង្ឃលោករៀបចំធ្វើពិធីក្រាលគ្រងកឋិន។ ឧបាសកអាចនៅមើលបាន តែត្រូវអង្គុយឲ្យឆ្ងាយពីព្រះសង្ឃ ចំនួន ២ហត្ថ ១ចំអាម ពោលគឺចន្លោះពីឧបាសក ទៅ ព្រះសង្ឃ ត្រូវមានប្រវែង ១ហត្ថ ១ចំអាម។

# ៩-ឯកសារផ្សេងៗជាប់ទំនៀមទម្លាប់ខ្មែរ

## ៩-១ មហាសង្ក្រាន្ត

*មុននឹងអធិប្បាយអំពី មហាសង្ក្រាន្ត ជាទូទៅ ខ្ញុំសូមលើកយក សង្ក្រាន្ត គឺថ្ងៃចូលឆ្នាំថ្មី ឆ្នាំ ២០០៧ ជាឧទាហរណ៍ ។*

*នេះនឹងគណនាឆ្នាំកុរ នព្វស័កព.ស. ២៥៥១ ឆ្នាំនេះសង្ក្រាន្តចូលមកនៅថ្ងៃសៅរ៍ ១២កើតខែចេត្រត្រូវនឹងថ្ងៃទី១៤ ខែមេសា ឆ្នាំ២០០៧ វេលាម៉ោង១២នឹង២៨នាទី ព្រះអាទិត្យចរចេញពី មីនរាសី ចូលទៅឋិតនៅក្នុងមេសរាសី ដើរផ្លូវគោចរវិថីតាមវង់គោចររបស់ខ្លួន មានទេពធីតាមួយអង្គដែលត្រូវវេន ចុះមករក្សាលោកធាតុ នាមមហោទរា បុត្រីទី៧នៃកបិលមហាព្រហ្ម ទ្រង់គ្រឿងអលង្ការនិលរតន៍ (ត្បូងពណ៌ខៀវ) សៀតផ្កាត្រកៀត (ពួកត្រាវ) ភក្សាហារសាច់ទ្រាយ ទ្រង់គង់ពាក់ចៀងលើសត្វក្ងោក ព្រះហស្តស្តាំកាន់ចក្រ  ព្រះហស្តឆ្វេងកាន់ត្រីសូល៍ នាំអស់ទេពកញ្ញាទាំងមួយសែនកោដិ ទៅកាន់គុហាកែវឈ្មោះគន្ធមាលី នាទីភ្នំកៃលាស នៅហិមពាន្ត ទីប្រតិស្ឋានទុកព្រះសិរសា កបិលមហាព្រហ្ម ជាព្រះបិតា តម្កល់លើពានមាសនាំចេញមកដង្ហែប្រទក្សិណភ្នំព្រះសុមេរុតាមផ្លូវព្រះអាទិត្យ ចរជាគំរប់៦០នាទី ទើបនាំទៅតម្កល់ទុកនៅកន្លែងដើមវិញ ហើយប្រជុំទេវបុត្រទេវធីតាចូលទៅស្រង់ទឹកក្នុងមហាស្រះអនោតត្តដែលមានទឹកហូរចេញពីបំពង់កែវត្រជាក់ក្សេមក្សាន្ត ទើបនាំគ្នាទៅសមាទានសីល ក្នុងភគវតីសភា ដែលវិស្សុកម្មទេវបុត្រនិម្មិតថ្វាយដើម្បីបន្ទោ បង់អពមង្គលឲ្យជ្រះស្រឡះ  ចំរើនសិរីសួស្តីជយមង្គលអាយុ យឺនយូរដល់ទេវតា និងមនុស្សលោក តាំងពីឆ្នាំថ្មីចូលមកដល់ បានសុខក្សេមក្សាន្តតរៀងទៅ។ ថ្ងៃអាទិត្យ១៣កើតខែចេត្រ ជាវារៈវនប័ត ថ្ងៃចន្ទ១៤កើតខែចេត្រ ជាវារៈឡើងស័ក គម្រប់សង្ក្រាន្ត៣ថ្ងៃចូលជាសកលឆ្នាំកុរ នព្វស័ក ពស២៥៥១ តរៀងទៅ។     ក្នុងឱកាសសង្ក្រាន្តទាំង៣ថ្ងៃនេះសូមប្រជាជនប្រុសស្រីរៀបចំទេវតាពលីទទួលស្វាគមន៍ទេវតាឆ្នាំថ្មី និង  អុជប្រទីប ផ្កាលា ហើយខិតខំលះបង់ចិត្តអាក្រក់ដែលកើតមានក្នុងឆ្នាំចាស់នោះឲ្យជ្រះស្រឡះតាំងចិត្តប្រព្រឹត្តល្អក្នុងឆ្នាំថ្មី*

ធ្វើបុណ្យឲ្យទានតាមប្រពៃណី រក្សាសីលឲ្យបានខ្ជាប់ខ្ជួន នោះទេវតានឹងឲ្យពរសព្វសាធុការលោកអ្នកនឹងមានសិរីសួស្តីសុភមង្គលវិបុលសុខគ្រប់ប្រការ ត្រជាក់ត្រជុំ អាយុ យឺនយូរ តរៀងទៅ។

តទៅនេះ ដើម្បីងាយយល់អំពីប្រតិទិនខ្មែរ ខ្ញុំចែកអត្ថបទជា៣ចំពូក។

***<u>ចំពូកទី១</u>* - *សុរិយគតិ នឹង ចន្ទគតិ***

*នៅប្រទេសខ្មែរយើង មុនសម័យបារាំង យើងប្រើ ថ្ងៃ ខែ ឆ្នាំ ទៅតាមចន្ទគតិសុទ្ធ តែមកដល់សម័យបារាំង យើងមានប្រើចន្ទគតិផងសុរិយគតិផង លុះក្រោយសម័យបារាំង យើងប្រើតែសុរិយគតិសុទ្ធ។ ដោយហេតុថាប្រជាជនប្រទេសខ្មែរយើង កាន់ព្រះពុទ្ធសាសនា តែងនាំគ្នាធ្វើបុណ្យទានទៅតាមប្រពៃណី និង ទៅតាមព្រះពុទ្ធបញ្ញត្តិដែលយកតាមចន្ទគតិទាំងអស់ ដូច្នេះយើងគួរយល់ន័យខ្លះៗដែលប្រើក្នុងចន្ទគតិ។*

*១- **<u>រដូវ</u>** - តាមចន្ទគតិ រដូវមាន៣ ហើយរដូវនីមួយៗមានរយៈពេល៤ខែ គឺ:*

** <u>ហេមន្តរដូវ</u> ជារដូវទឹកសន្សើមឬរដូវរងា ចាប់ផ្តើមពី ១រោចខែកត្តិកដល់១៥កើតខែផល្គុន*

** <u>គិម្ហរដូវ</u> ជារដូវក្តៅ ចាប់ផ្តើមពី ១រោចខែផល្គុនដល់១៥កើតខែអាសាឍ*

** <u>វស្សានរដូវ</u> ជារដូវភ្លៀងផ្គរ ចាប់ផ្តើមពី ១រោចខែអាសាឍដល់១៥កើតខែកត្តិក។*

*តែរដូវតាមចន្ទគតិនោះមិនទៀងទាត់ទេ បើច្រើនឆ្នាំទៅ រដូវរងានឹងក្លាយទៅជារដូវក្តៅៗក្លាយទៅជារដូវរងាមិនខាន ។ ព្រោះតាមចន្ទគតិមួយជុំរដូវ មាន៣៥៤ថ្ងៃ ហើយចំពោះសុរិយគតិវិញ មួយជុំរដូវ មាន៣៦៥ថ្ងៃ ហើយរដូវក្តៅរងាក្តី រដូវភ្លៀងក្តី រដូវផ្កា-ផ្លែឈើក្តី សុទ្ធតែតាមសុរិយគតិទាំងអស់។*

*ដូច្នេះហើយបានជាពេលក្រោយមក វេលាចាប់ផ្តើមប្រើចុល្លសករាជទើបត្រឡប់ប្រើតាមសុរិយគតិវិញ ហើយកំណត់យកចូលឆ្នាំក្នុងខែចេត្រដែលជារដូវក្តៅ។*

*(ឯកសារលេខ ៤-៥)*

*២- **<u>ឆ្នាំ</u>** - តាមចន្ទគតិ ឆ្នាំមាន៣យ៉ាងគឺ:*

** ឆ្នាំជាសុភាពឬឆ្នាំប្រក្រតី មាន៣៥៤ថ្ងៃ ចែកចេញជា១២ខែ*

* ឆ្នាំចន្ទ្រាធិមាសឬឆ្នាំអធិកវារៈ មាន៣៥៥ថ្ងៃ ចែកចេញជា១២ខែ

* ឆ្នាំអធិកមាស មាន៣៨៤ថ្ងៃ ចែកចេញជា១៣ខែ គឺខែអាសាឍពីរដង ហៅបឋមាសាឍ និងទុតិយាសាឍ ។

<u>ឈ្មោះឆ្នាំទាំង១២ គឺ</u>:

ឆ្នាំទី១ ជូត ឆ្នាំកណ្ដុរ

ឆ្នាំទី២ ឆ្លូវ ឆ្នាំគោ

ឆ្នាំទី៣ ខាល ឆ្នាំខ្លា

ឆ្នាំទី៤ ថោះ ឆ្នាំទន្សាយ

ឆ្នាំទី៥ រោង ឆ្នាំនាគ

ឆ្នាំទី៦ ម្សាញ់ ឆ្នាំពស់

ឆ្នាំទី៧ មមី ឆ្នាំសេះ

ឆ្នាំទី៨ មមែ ឆ្នាំពពែ

ឆ្នាំទី៩ វក ឆ្នាំស្វា

ឆ្នាំទី១០ រកា ឆ្នាំមាន់

ឆ្នាំទី១១ ច ឆ្នាំឆ្កែ

ឆ្នាំទី១២ កុរ ឆ្នាំជ្រូក ។

៣- **<u>ខែ</u>** - តាមចន្ទគតិ ខែមាន១២ ចែកជាពីរចំណែកគឺ:

* ខែ ដែលមាន៣០ថ្ងៃ ហៅ ខែពេញ (ញី)

* ខែ ដែលមាន២៩ថ្ងៃ ហៅ ខែខាត (ឈ្មោល)

ខែនីមួយៗចាប់ផ្ដើមពី ១កើត ដល់ ១៥កើត និង ពី ១រោច ដល់ ១៤រោច(ខែខាត) ឬ ១៥រោច(ខែពេញ)

-ថ្ងៃ៨កើតនិង ថ្ងៃ៨រោច ហៅ <u>ថ្ងៃសីល</u>

-ថ្ងៃ១៤កើត និង ថ្ងៃ១៣រោច(ខែខាត) ឬ ១៤រោច(ខែពេញ) ហៅ <u>ថ្ងៃកោរ</u>

-ថ្ងៃ១៥កើត ហៅថ្ងៃ <u>ពេញបូណ៌មី</u>

- ថ្ងៃ ១៤រោច(ខែខាត) ឬ ១៥រោច(ខែពេញ) ហៅថ្ងៃ <u>ដាច់ខែ</u> ។

ឈ្មោះខែនីមួយៗមានឈ្មោះដែលហោរាហៅឫក្សមានដួងជាសំគាល់។

ឧទាហរណ៍

ឫក្សមិគសិរមានដួងក្តាន់ជាសំគាល់

ខែទី១ មិគសិរ ក្តាន់ ២៩ថ្ងៃ

ខែទី២ បុស្ស ក្តាម ៣០ថ្ងៃ

ខែទី៣ មាឃ ស្វាព្រាហ្មណ៍ ២៩ថ្ងៃ

ខែទី៤ ផល្គុន គោ ៣០ថ្ងៃ

ខែទី៥ ចេត្រ ខ្លា ២៩ថ្ងៃ

ខែទី៦ ពិសាខ ក្របី ៣០ថ្ងៃ

ខែទី៧ ជេស្ឋ ពពែ ២៩ ឬ ៣០ថ្ងៃ

ខែទី៨ អាសាឍ សីហ: ៣០ថ្ងៃ

ខែទី៩ ស្រាពណ៍ ផ្កាឈើ ២៩ថ្ងៃ

ខែទី១០ ភទ្របទ រមាស ៣០ថ្ងៃ

ខែទី១១ អស្សុជ សេះ ២៩ថ្ងៃ

ខែទី១២ កត្តិក កូនមាន់ ៣០ថ្ងៃ ។

៤ -ថ្ងៃ - ថ្ងៃទាំងអស់មាន៧ គឺ :

អាទិត្យ ចន្ទ អង្គារ ពុធ ព្រហស្បតិ៍ សុក្រ សៅរ៍ ។

ខ្មែរយើងរាប់ថ្ងៃអាទិត្យជាថ្ងៃទី១ ថ្ងៃនីមួយៗចប់នៅវេលាអធ្រាត្រ ។ ប៉ុន្តែ តាមពុទ្ធបញ្ញត្តិ ថ្ងៃនីមួយៗចប់នៅពេលអរុណរះ។

## ចំពូកទី២ - មហាសង្ក្រាន្ត

ជាធម្មតា ប្រតិទិនសុរិយគតិ-ចន្ទគតិ ត្រូវបានរៀបរៀងដោយក្រុមហោរាសាស្ត្រ និង ទំនៀមទម្លាប់នៃព្រះបរមរាជវាំង។

១ - ***<u>សករាជ</u>*** - សករាជមានន័យថា "កាល,យុគ,សម័យ" សំរាប់សំគាល់ព្រឹត្តិការណ៍ ឬហេតុអស្ចារ្យណាមួយ។ សករាជដែលប្រើ ក្នុងប្រទេសខ្មែរតាំងពីបូរាណកាលមក មាន៖

១- <u>បូរាណសករាជ</u>

ចាប់ផ្តើម៩១ឆ្នាំមុនពុទ្ធសករាជតែត្រូវបានយើងឈប់ប្រើយូរហើយពុំដឹងហេតុអ្វីទេ

២- <u>ពុទ្ធសករាជ</u> ចាប់ផ្តើម៥៤៤ឆ្នាំមុនគ្រិស្តសករាជ រាប់ពីថ្ងៃ ព្រះពុទ្ធទ្រង់បរិនិព្វានបាន១ថ្ងៃ គឺ ពី១រោចខែពិសាខឆ្នាំម្សាញ់

៣- <u>មហាសករាជ</u> ចាប់ផ្តើមក្នុងឆ្នាំ៧៩គ្រិស្តសករាជ ត្រូវនឹងឆ្នាំថោះ។ ខ្មែរយើងនិយមប្រើ មហាសករាជ នៅសម័យអង្គរ និង មុនសម័យអង្គរ។

ឯកសារជាច្រើននិយាយពីប្រវត្តិសករាជនេះ តែមិនដូចគ្នាសុទ្ធសាធទេ។ មាននិទាន ថានៅប្រទេសឥណ្ឌាខាងត្បូងមានការរាតត្បាតយ៉ាងខ្លាំងពីពួកសកៈ។ ក្រោយពីបានមហាជោគជ័យយ៉ាងសម្បើមមក ពួកនេះបានលើកក្សត្រិយ៍របស់ ខ្លួនព្រះនាម "<u>សាលីវាហនៈ</u>" ឲ្យឡើងសោយរាជ្យ។ ស្តេចអង្គនេះបានតាំងសករាជរបស់ខ្លួនហៅថាសកៈ។

រាជពង្សាវតារខ្មែរថាព្រះបាទសម្តេចព្រះ "អរិដ្ឋពលពាហនោព្រះកេតុមាលា" បានតាំងសករាជមួយដែរក្នុងព.ស៦២៣។

(ឯកសារលេខ៤-៩)

ឯកសារនិងសីលាចារិកនៅប្រទេសខ្មែរ និងនៅប្រទេសឥណ្ឌា សរសេរថាសកៈ ឥតមានប្រើពាក្យមហាសករាជដូចឥឡូវនេះទេ ។

៤- <u>ចុល្លសករាជ</u>

ចាប់ផ្តើមក្នុងឆ្នាំ ៦៣៩ នៃគ្រិស្តសករាជ ត្រូវនឹងឆ្នាំកុរ។ គេពុំបានដឹងច្បាស់ពីប្រវត្តិ សករាជនេះទេ គ្រាន់តែដឹងថាប្រហែលចាប់ផ្តើមនៅប្រទេសឥណ្ឌាមុនគេ។ ពង្សាវតារភូមាបានអះអាងថាចុល្លសករាជជាស្នាព្រះហស្តរបស់ព្រះសង្ឃមួយអង្គ ព្រះនាម"សង្ករត្នមុនេរ្យាហន"។ ព្រះសង្ឃ អង្គនេះជាអ្នកជំនាញខាងក្បួនហោរាទស្សន៍

ទាយ ក្រោយពីចាកសិក្ខាបទ និងដេញស្តេចសោយរាជ្យរួចហើយ ក៏តែងតាំងខ្លួនឯងជាស្តេចនៅភូមា ។ (ឯកសារលេខ ៤-៧)

រាជពង្សាវតារខ្មែរយើងថាព្រះបាទបទុមសុរិយវង្សបានតាំងសករាជមួយដែរក្នុង ព.ស១១៨៣។ (ឯកសារលេខ ៤-៩)

២ - ***ស័ក*** - ស័កមានទាំងអស់១០គឺ:

ឯកស័ក ទោស័ក ត្រីស័ក ចត្វាស័ក បញ្ចស័ក ឆស័ក សប្តស័ក អដ្ឋស័ក នព្វស័ក សំរឹទ្ធិស័ក

ខ្មែរយើងប្រើស័កភ្ជាប់ជាមួយសករាជ គឺថាស័ករបស់ឆ្នាំ។ ឧទាហរណ៍ ឆ្នាំកុរ នព្វស័ក ពស២៥៥១។

យើងពុំដឹងច្បាស់ថាតើអ្នកណាបានបង្កើតស័កនេះទេ គួរកត់សំគាល់ថានៅប្រទេសផ្សេងៗឯទៀតដែលមានប្រជាជនកាន់ព្រះពុទ្ធសាសនាដូចប្រទេសកម្ពុជាដែរ ដូចជាប្រទេសលង្កា គេគ្មានប្រើស័ក និង ឈ្មោះឆ្នាំទេ គេថាពុទ្ធសករាជ២៥០០ ឬគ្រិស្តសករាជ១៩៥៦តែម្តង។ នៅប្រទេសឥណ្ឌា ក្នុងអាណាខេត្រខ្លះគេប្រើតែសករាជដូចប្រទេសលង្កាដែរ។ ប្រទេសភូមាក៏គ្មានប្រើឈ្មោះឆ្នាំឬស័កដែរ គេនិយមប្រើសករាជតែម្តងដូចជាពស២៥០០។ សៀវភៅរបស់លោកភួងទួន បញ្ជាក់ថា ស័កកើតជាមួយចុល្លសករាជគឺថាចុល្លសករាជកើតឆ្នាំណា គេសន្មតឆ្នាំនោះជាឯកស័ក។ចំណែកឯសៀវភៅរបស់លោកលី សុវី ថាស័កកើតក្នុងសម័យព្រះបាទកេតុមាលាបានឡើងសោយរាជ្យ។ ប្រជានុរាស្ត្របានតែងតាំងមហាសករាជពីឆ្នាំថោះពុទ្ធសករាជ៦២៣។បើយោងទៅលើប្រវត្តិខាងលើនេះឃើញថាស័កជារបស់មហាសករាជឬចុល្លសករាជ មិនមែនស័ករបស់ព្រឹត្តិការណ៍ណាមួយឡើយ។ សូមជួយសង្កេត ឧទាហរណ៍ខាងក្រោមនេះ

ឆ្នាំគ.ស២០០៧ត្រូវនឹងឆ្នាំកុរ មហាសករាជ១៩២៩ ត្រូវនឹង ចុល្លសករាជ១៣៦៩ ត្រូវនឹង ព.ស២៥៥១ នព្វស័ក។ យើងឃើញថានព្វស័ក(លេខខាងចុង)ត្រូវនឹងមហាសករាជនឹងចុល្លសករាជមែន ចុះហេតុអ្វីបានជាយើងថា ឆ្នាំកុរព.ស២៥៥១ នព្វស័កដែរ? ចម្លើយខាងលើនេះមាននៅក្នុងសៀវភៅ "បញ្ជាក់សករាជ" របស់លោក

ភួង នួន ភ្នំពេញ ១៩៥៧ ពិនិត្យដោយសម្តេចសង្ឃរាជជួន ណាត ដូចតទៅៈ ព្រះពុទ្ធទ្រង់បរិនិព្វានក្នុងឆ្នាំម្សាញ់បញ្ចស័ក។ បើយើងរាប់ថយក្រោយមកវិញ ឃើញថាឆ្នាំម្សាញ់ដែលព្រះពុទ្ធទ្រង់បរិនិព្វាននៅលើនព្វស័កទេ។

បើស័កកើតក្រោយពុទ្ធសករាជ ហេតុអ្វីយើងមានប្រើស័កក្នុងឆ្នាំម្សាញ់មុនមានមហាសករាជ និងចុល្លសករាជហើយឈ្មោះស័កមិនត្រូវទៀតផង?

លោកឧកញ៉ាហោរាធិបតី អ៊ុម យក់ មានប្រសាសន៍ ថា ឯកស័កដែលមានសព្វថ្ងៃនេះចាប់ផ្តើមប្រើជាមួយគ្នានឹងចុល្លសករាជហើយសំរាប់តែចុល្លសករាជទេគឺថាចុល្លសករាជកើតឆ្នាំណា គេសន្មតឆ្នាំនោះជាឯកស័ក។

ឯបញ្ចស័កដែលគេកំណត់ទុកក្នុងឆ្នាំម្សាញ់កាលព្រះពុទ្ធទ្រង់បរិនិព្វាននោះគ្រាន់តែជាទីសំគាល់ខន្ធ៥នៃព្រះអង្គ ដែលរំលត់ក្នុងពេលនោះ។

៣ - **<u>ពុទ្ធសករាជខុសគ្នា</u>** - ក្នុងឆ្នាំវកខ្មែរត្រូវនឹងគ្រិស្តសករាជ <u>១៩៥៦</u> ភូមាកំណត់ថាពុទ្ធសករាជ២៥០០ឆ្នាំ ចុល្លសករាជ១៣១៨ឆ្នាំ បានធ្វើបុណ្យធំមួយដែលយើងហៅថា "<u>បុណ្យពាក់កណ្តាលពុទ្ធសាសនា</u>"។

ចំណែកស្រុកខ្មែរយើងបុណ្យឆ្លងចេតិយសារីរិកធាតុបានប្រព្រឹត្ត ទៅនៅថ្ងៃអាទិត្យ ១៤កើតខែពិសាខឆ្នាំរកានព្វស័ក២៥០០ត្រូវនឹងថ្ងៃ១២ឧសភា <u>១៩៥៧</u>។ ហេតុអ្វីក៏ខុសគ្នា១ឆ្នាំ?នៅប្រទេសឥណ្ឌា លង្កា និង ភូមា គេប្រើ "ពុទ្ធសករាជបច្ចុប្បន្ន" គឺឆ្នាំដំបូងរបស់ពុទ្ធសករាជជាឆ្នាំទី១ ចំណែកឯ ប្រទេសខ្មែរ សៀម លាវ គេរាប់ឆ្នាំដំបូងរបស់ពុទ្ធសករាជជាឆ្នាំទី០(សូន្យ) លុះកន្លងទៅបានមួយឆ្នាំ ទើបហៅថាឆ្នាំទី១ ។ (ឯកសារលេខ ៤-៧)

សេចក្តីអធិប្បាយខាងលើបញ្ជាក់ថាខ្មែរយើងរាប់ឆ្នាំ២៥០០ លុះត្រាតែឆ្នាំនោះកន្លងផុត។ តែក្រោយពីគ.ស១៩៥៧មក សម្តេចសង្ឃ ជួន ណាត សម្រេចឲ្យយកពុទ្ធសករាជបច្ចុប្បន្នមកប្រើវិញដូចប្រទេសនានាដែលកាន់ពុទ្ធសាសនាទាំងអស់ (ភួង នួន) ។

៤ - **<u>អធិកមាស</u>** - ឆ្នាំមាន១៣ខែ ឧបមាដូចនៅថ្ងៃពេញបូណ៌មីខែមាឃឆ្នាំឆ្លូវសប្តស័ក ចុល្លសករាជ១២៨៧ ព្រះចន្ទស្ថិតក្នុងឫក្សខែបុស្ស ពេញបូណ៌មីខែផល្គុនព្រះ

ចន្ទស្ថិតក្នុងឫក្សខែមាឃ។ គោចរព្រះចន្ទយឺតដូច្នេះបានជាឆ្នាំខាល អដ្ឋស័ក ចុល្លសករាជ ១២៨៨ត្រូវបន្ថែមខែអាសាឍជា បឋមាសាឍ និង ទុតិយាសាឍ ដើម្បីឲ្យព្រះចន្ទទៅស្ថិតនៅក្នុងឫក្សរបស់ខ្លួន។ បណ្តាខែទាំង១២ មានខែ៣ គឺ ផល្គុន អាសាឍ នឹងភទ្របទ មានដួងមួយគូៗៈ

-ផល្គុន មានដួងពីរហៅ បុព្វផល្គុណី (គោឈ្មោល) នឹង ឧត្តរផល្គុណី(គោញី)

-អាសាឍ មានដួងពីរហៅ បុព្វាសាឍ (រាជសីហ៍ឈ្មោល) នឹង ឧត្តរាសាឍ (រាជសីហ៍ញី)

-ភទ្របទ មានដួងពីរហៅ បុព្វភទ្របទា(រមាសឈ្មោល) នឹង ឧត្តរភទ្របទា(រមាសញី)

ហេតុនេះហើយបានជាពីបូរាណ ហោរាអាចលើក៣ខែនេះ បើរាសីចក្ររិលដល់ខែណាត្រូវលើកខែនោះដើម្បីបង្គ្រប់ប្រតិទិន គឺថាដើម្បីឲ្យមានចំនួនថ្ងៃស្មើគ្នានឹងចំនួនថ្ងៃសុរិយគតិ ។ ប៉ុន្តែតាមទំនៀមទម្លាប់ គេនិយមលើកខែ តែខែអាសាឍ ហៅអាសាឍ ទី ២ ឬ ទុតិយាសាឍ ។(សូរ្យយាត្រឡើងស័ក អ៊ុម ពូវ ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ១៩៧០)

៥- <u>**ចន្ទ្រាធិមាស**</u> - បន្ថែម១ថ្ងៃក្នុងខែជេស្ឋ ឯការបន្ថែម១ថ្ងៃក្នុងខែជេស្ឋនោះគឺគោចរព្រះចន្ទលឿនហួសវិញ ឧបមានៅ១រោចខែអាសាឍព្រះចន្ទស្ថិតក្នុងឫក្ស២រោច។

៦- <u>**សង្ក្រាន្ត**</u> មានន័យថាដំណើរព្រះអាទិត្យចូលកាន់រាសីថ្មីគឺដំណើរដាច់ឆ្នាំចាស់ផ្លាស់ឆ្នាំថ្មីឬពិធីចូលឆ្នាំថ្មី។ យើងដឹងថា ឆ្នាំចន្ទគតិខ្លីជាងឆ្នាំសុរិយគតិ។ ដោយហេតុថាចូលឆ្នាំយកតាមសុរិយគតិ ដូច្នេះទើបមានបន្ថែម១ថ្ងៃឬ១ខែក្នុងឆ្នាំខ្លះ។ តាមក្បួនហោរាសាស្រ្ត ការបន្ថែម១ថ្ងៃឬ១ខែមកពីគោចរព្រះចន្ទលឿនឬយឺតបន្តិចៗរាល់ឆ្នាំ ព្រះចន្ទមកឋិតក្នុងឫក្សពុំបានទៀងទាត់ហើយចូលក្នុងឫក្សផ្សេងទៅវិញ។ ហោរាសាស្រ្តនិយាយរាសី កាលណាប្រើជារង្វាស់រង្វាល់ ទាំងអស់មាន១២ រាប់ពីរាសី០ដល់រាសី១១។ មួយរាសីមាន៣០អង្សាហើយ១អង្សាមាន៦០លិប្តា។ ហោរាកំណត់ថ្ងៃចូលឆ្នាំនៅវេលាសុរិយាធ្វងពី រាសី១១ចូលទៅដល់ រាសី០ ហៅថ្ងៃសង្ក្រាន្ត។

ពិធីចូលឆ្នាំមាន៣ថ្ងៃ (ឆ្នាំខ្លះមាន៤ថ្ងៃ)។ ថ្ងៃទី១ ហៅថ្ងៃចូលឆ្នាំ ថ្ងៃកណ្ដាលហៅវនប័ត ថ្ងៃចុងក្រោយហៅថ្ងៃឡើងស័ក។ ហោរាគណនាជាដំបូងរកថ្ងៃឡើងស័ក គឺថ្ងៃឡើងស័កនេះហើយដែលផ្ដល់ថ្ងៃឯទៀត មានថ្ងៃចូលឆ្នាំ ថ្ងៃវនប័តជាដើម។ ត្រូវចងចាំថា តាមក្បួនហោរាសាស្ត្រខ្មែរយើង **ថ្ងៃឡើងស័កត្រូវនៅក្នុងចន្លោះពី ៦កើតខែចេត្រ ទៅ ៥កើតខែពិសាខ។** បើថ្ងៃឡើងស័កនៅចន្លោះពី ៦កើតខែចេត្រ ទៅ ៩រោចខែចេត្រ ឆ្នាំនោះជាឆ្នាំ ជាសុភាពឬឆ្នាំប្រក្រតីមាន១២ខែ។ បើថ្ងៃឡើងស័កនៅចន្លោះពី ១០រោចខែចេត្រ ទៅ ៥កើតខែពិសាខ ឆ្នាំនោះជាឆ្នាំអធិកមាសមាន១៣ខែ។ រូបមន្តដែលហោរាប្រើក្នុងការគិតលេខផ្សេងៗ ដើម្បីធ្វើមហាសង្ក្រាន្ត សន្មតឆ្នាំទី១ របស់សករាជនីមួយៗនៅថ្ងៃឡើងស័កគឺ:

| | |
|---|---|
| -បូរាណស័ករាជ១ | ថ្ងៃពុធ៨កើតខែចេត្រឆ្នាំកុរ |
| -ពុទ្ធស័ករាជ១ | ថ្ងៃព្រហស្បតិ៍១៣កើតខែចេត្រឆ្នាំម្សាញ់ |
| -មហាស័ករាជ១ | ថ្ងៃពុធ១១រោចខែចេត្រឆ្នាំរោះ |
| -ចុល្វស័ករាជ១ | ថ្ងៃចន្ទ១២កើតខែចេត្រឆ្នាំកុរ |

**<u>ចំពូកទី៣</u> - របៀបរកឈ្មោះឆ្នាំ និង ស័ក**

យើងអាចដឹងបានដោយងាយនូវ ឆ្នាំ ឬស័ក បើយើងដឹងសករាជណាមួយ។

១ - **រកឈ្មោះឆ្នាំ** - ខ្មែរយើងរាប់ឆ្នាំជូតជាទី១.....ឆ្នាំកុរជាទី១២

-បើយើងស្គាល់ពុទ្ធសករាជ យើងត្រូវរក ចំនួនសេស = (ពស + ៥) ចែក ១២

-បើយើងស្គាល់មហាសករាជ យើងត្រូវរក ចំនួនសេស = (មហ + ៣) ចែក ១២

-បើយើងស្គាល់ចុល្វសករាជ យើងត្រូវរក ចំនួនសេស = (ចល + ១១) ចែក ១២

-បើយើងស្គាល់គ្រិស្តសករាជ យើងត្រូវរក ចំនួនសេស = (គស + ៩) ចែក ១២

ចំនួនសេសនេះហើយជាលេខរៀងរបស់ឈ្មោះឆ្នាំ (ក្រោយថ្ងៃឡើងស័ក) ។

ក-ឧទាហរណ៍ ព.ស២៥៥០

២៥៥០+៥=២៥៥៥ ; ២៥៥៥ ចែក ១២ បានចំនួនសេស ១១ ; ឆ្នាំទី១១ គឺឆ្នាំច

**ខ**- ឧទាហរណ៍ គ.ស២០០៧ (សករាជក្រោយថ្ងៃឡើងស័ក)

២០០៧+៩=២០១៦ ; ២០១៦ ចែក ១២ បានចំនួនសេស ០ ; ឆ្នាំទី០ = ឆ្នាំទី១២ គឺឆ្នាំកុរ

២ - **រកស័ក** -

-ចំពោះមហាសករាជនឹងចុល្លសករាជ លេខខាងចុងជាលេខស័ក។

-បើពុទ្ធសករាជគឺលេខខាងចុងរបស់ (ព.ស - ២)

ឧទាហរណ៍ ព.ស២៥៥១ ;

(២៥៥១ - ២) = ២៥៤៩ ; លេខ៩ គឺ នព្វស័ក

បើគ្រិស្តសករាជ (សករាជក្រោយថ្ងៃឡើងស័ក)

គឺលេខខាងចុងរបស់ (គ.ស + ២)

ឧទាហរណ៍ គ.ស២០០៧ ;

(២០០៧ + ២) = ២០០៩ ; លេខ៩ គឺ នព្វស័ក

មុននឹងបញ្ចប់អត្ថបទសង្ខេបនេះ ខ្ញុំ រស់ វ៉ាន់ថា សូមអរគុណដល់លោក ម៉ក់ ភីន ដែលតែងតែបានផ្តល់បន្ថែមឯកសារជាច្រើនក្នុងការស្រាវជ្រាវនានារបស់ខ្ញុំ។ ម្យ៉ាងទៀត ខ្ញុំយល់ថាអត្ថបទនេះ ច្បាស់ជាមានការភាន់ច្រឡំឬការខ្វះខាតខ្វះមិនខាន សូមអស់លោកអ្នកអានមេត្តាអធ្យាស្រ័យ និង សូមជួយកែតម្រូវ និងបំពេញ ឲ្យរឹតតែបានប្រសើរថែមទៀតផងចុះ ខ្ញុំសូម អរគុណទុកជាមុន។

## ៩-២ កបិលមហាព្រហ្ម និង ធម្មបាល - ទេពធីតា៧អង្គ

ក្នុងកាលដើមនៃភទ្ទកប្បនេះ មានបុរសម្នាក់ឈ្មោះ ធម្មបាលជាបុត្រសេដ្ឋី រៀនចេះចប់ត្រៃវេទ តាំងពីអាយុ៧ឆ្នាំ។ សេដ្ឋីសាងប្រាសាទឲ្យនៅជិតដើមជ្រៃធំមួយ។ ធម្មបាលកុមារចេះទាំងភាសាបក្សីទាំងពួងផង ហើយបានជាអាចារ្យសម្តែងមង្គលផ្សេងៗ ដល់មនុស្សទាំងពួង។ គ្រានោះ មនុស្សលោករមែងរាប់អានព្រះមហាព្រហ្ម និង កបិលមហាព្រហ្ម ថាជាអ្នកសម្តែងមង្គលដល់មនុស្សទាំងពួង។ កាលកបិលមហាព្រហ្មជ្រាបពត៌មាននោះ ក៏ចុះមកសួរបញ្ហានឹងធម្មបាល៣ខ

សន្យាថាបើដោះប្រស្នាបានក្នុងវេលា៧ថ្ងៃនឹងកាត់ក្បាលបូជាធម្មបាលកុមារ
បើដោះមិនបាននឹងកាត់ក្បាលធម្មបាលវិញ។
លុះកន្លង៦ថ្ងៃហើយក៏ធម្មបាលគិតប្រស្នានោះមិនឃើញដឹងខ្លួនថានឹងត្រូវស្លាប់ដោយអាជ្ញាកបិលមហាព្រហ្មជាប្រាកដ ដូច្នេះគួរអញរត់ទៅពួនលាក់ខ្លួនឲ្យស្លាប់បង់ដោយខ្លួនឯង ទើបចុះពីប្រាសាទទៅដេកនៅក្រោមដើមត្នោតមួយគូ ដែលមានសត្វឥន្ទ្រីញីឈ្មោលនៅ។ វេលាយប់ ឥន្ទ្រីញីសួរឥន្ទ្រីឈ្មោលថា ព្រឹកស្អែកនេះយើងបានអាហារស្អី? ឥន្ទ្រីឈ្មោលឆ្លើយថា យើងនឹងបានសាច់ធម្មបាលកុមារដែលត្រូវកបិលមហាព្រហ្មសម្លាប់ព្រោះដោះប្រស្នាមិនរួច។ ឥន្ទ្រីញីសួរថាប្រស្នានោះដូចម្តេច? ឥន្ទ្រីឈ្មោលឆ្លើយថា វេលាព្រឹកសិរីស្ថិតនៅទីណា? ត្រូវឆ្លើយថានៅ
មុខ ហេតុនោះមនុស្សទាំងឡាយត្រូវយកទឹកលប់មុខ។ខមួយទៀតថាថ្ងៃត្រង់សិរីស្ថិតនៅទីណា? ត្រូវឆ្លើយថានៅទ្រូង ហេតុនោះមនុស្សទាំងឡាយត្រូវយកទឹកលាបទ្រូង។ ខមួយទៀតថាវេលាល្ងាចសិរីស្ថិតនៅទីណា? ត្រូវឆ្លើយថានៅជើង ហេតុនោះមនុស្សទាំងឡាយត្រូវយកទឹកលាងជើង។ធម្មបាលកុមារបានឮដូច្នោះក៏ត្រឡប់ទៅប្រាសាទវិញ។
ព្រឹកឡើង ធម្មបាលកុមារ ក៏ឆ្លើយដោះស្រាយតាមដែលបានឮមកទើបកបិលមហាព្រហ្មហៅបុត្រីទាំង៧នាក់មកប្រាប់ថាឥឡូវបិតាត្រូវកាត់ក្បាលបូជាធម្មបាលកុមារ តែបើដាក់ក្បាលនោះលើផែនដីក៏នឹងកើតជាភ្លើងឆេះលោកធាតុ បើបោះទៅលើអាកាសភ្លៀងក៏នឹងរាំង បើបោះទៅក្នុងមហាសមុទ្រទឹកក៏រីងស្ងួតអស់ ដូច្នេះសុំឲ្យកូនទាំង៧នាក់យកពានមាសមកទទួលក្បាល ថាហើយក៏កាត់ក្បាលហុចទៅនាងទុង្សាជាកូនច្បង ទើបនាងទុង្សាយកពានចូលទៅទទួលសិរ្សបិតា ហើយហែប្រទក្សិណភ្នំព្រះសុមេរុ ៦០នាទី ហើយក៏អញ្ជើញទៅប្រតិស្ឋានទុកក្នុងមណ្ឌប នៅក្នុងគុហាគន្ធមាលីភ្នំកៃលាស។
វិស្សកម្មក៏និម្មិតរោង ហៅ "ភគវតីសភា" ជាទីប្រជុំទេវតា លុះដល់គម្រប់ ១ឆ្នាំសង្ក្រាន្តនាងទេពធីតាទាំង៧ផ្លាស់គ្នាមកអញ្ជើញសិរ្ស កបិលមហាព្រហ្មចេញមកហែប្រទក្សិណភ្នំព្រះសុមេរុ៍រាល់ៗឆ្នាំ ហើយត្រឡប់ទៅទេវលោកវិញ។

*ឈ្មោះទេពធីតាដែលត្រូវវេនចុះមកអញ្ជើញសិរ្សកបិលមហាព្រហ្ម*

គឺទៅតាមថ្ងៃចូលឆ្នាំ បើ :

-ថ្ងៃអាទិត្យឈ្មោះទុង្សាសៀតផ្កាទទឹមគ្រឿងប្រដាប់បទុមរាគ(ពណ៌ក្រហម) ភក្សាហារផ្លែឧទុម្ពរ ព្រះហស្តស្តាំកាន់ច័ក្រ ព្រះហស្តឆ្វេងកាន់ស័ង្ខពាហនៈគ្រុឌ ។

-ថ្ងៃចន្ទ ឈ្មោះគោរាគសៀតផ្កាអង្គាបុស្ស គ្រឿងប្រដាប់មុក្តា (គជ់ខ្យង) ភក្សាហារប្រេង ព្រះហស្តស្តាំកាន់ព្រះខ័ន ព្រះហស្តឆ្វេងកាន់ឈើច្រត់ ពាហនៈខ្លា ។

-ថ្ងៃអង្គារ ឈ្មោះរាក្សសា សៀតផ្កាឈូក គ្រឿងប្រដាប់មោរា (កែវសម្បុរឆ្នូត) ភក្សាហារលោហិត ព្រះហស្តស្តាំកាន់ត្រីសូល៍ ព្រះហស្តឆ្វេងកាន់ធ្នូ ពាហនៈអស្សតរ (សេះ) ។

-ថ្ងៃពុធ ឈ្មោះមណ្ឌា សៀតផ្កាចម្ប៉ា គ្រឿងប្រដាប់ពិទូរ្យ ភក្សាហារទឹកដោះសប្បិ (ទឹកដោះថ្លា) ព្រះហស្តស្តាំកាន់ម្ជុល ព្រះហស្តឆ្វេងកាន់ឈើច្រត់ ពាហនៈលា។

-ថ្ងៃព្រហស្បតិ៍ ឈ្មោះកិរិណីសៀតផ្កាមណ្ឌា គ្រឿងប្រដាប់មរកត ភក្សាហារសណ្តែកលូ ព្រះហស្តស្តាំកាន់កង្វេរ ព្រះហស្តឆ្វេងកាន់កាំភ្លើង ពាហនៈដំរី។

-ថ្ងៃសុក្រ ឈ្មោះកិមិរា សៀតផ្កាចង្កុលណី គ្រឿងប្រដាប់បុស្សរាគ័ម (ពណ៌លឿង) ភក្សាហារចេកណាំវ៉ា ព្រះហស្តស្តាំកាន់ព្រះខ័ន ព្រះហស្តឆ្វេងកាន់ពិណ ពាហនៈក្របី ។

-ថ្ងៃសៅរ៍ឈ្មោះមហោទរាសៀតផ្កាត្រកៀត គ្រឿងប្រដាប់នីលរតន៍ ភក្សាហារសាច់ទ្រាយ ព្រះហស្តស្តាំកាន់ច័ក្រ ព្រះហស្តឆ្វេងកាន់ ត្រីសូល៍ ពាហនៈក្ងោក ។

**ទេពធីតាសុទ្ធតែសម្តែងកិរិយាផ្សេងៗដូចនេះ ៖**

ពី ព្រលឹម ដល់ ថ្ងៃត្រង់ ជិះឈរលែងដៃ

ពី ថ្ងៃត្រង់ ដល់ ព្រលប់ អង្គុយពាក់ចៀង

ពី ព្រលប់ ដល់ អធ្រាត្រ ដេកបើកភ្នែក

ពី អធ្រាត្រ ដល់ភ្លឺ ដេកធ្មេចភ្នែក

## ៩-៣ ប្រតិទិនបុណ្យទ្វាទសមាសពីឆ្នាំ ២០១៥ ដល់ ២០២៤

*ត្រស្តិសង្ក្រាន្ត* : ចាប់ពីថ្ងៃ១២ ដល់ ១៥រោច ខែផល្គុន (៤ថ្ងៃ) គឺដំណើរផ្តាច់ឆ្នាំចាស់ ផ្លាស់ឆ្នាំថ្មី មានពិធីសូត្រភាណយក្ខ លេងក្លេងត្រុដិ រាំត្រុដិ ច្រៀងត្រុដិ ។ត្រស្តិក្លាយពីសំស្ក្រិត ត្រុដិ (កាត់, ផ្តាច់) នៅខែផល្គុននេះ មានពិធីត្រស្តិសង្ក្រាន្ត ហៅព្រះរាជពិធីបញ្ចាន់ត្រស្តិ មានពិធីភាណយក្ស គឺមានសូត្រភាណយក្ស បណ្តេញយក្ស ខ្មោចបិសាច ។

| **ពិធីបុណ្យទ្វាទសមាស** | 2015 ឆ្នាំមមែសប្តស័ក ២៥៥៩ | 2016 ឆ្នាំវកអដ្ឋស័ក ២៥៦០ | **ពិធីបុណ្យទ្វាទសមាស** | 2017 ឆ្នាំរកានព្វស័ក ២៥៦១ | 2018 ឆ្នាំចសំរិទ្ធិស័ក ២៥៦២ |
|---|---|---|---|---|---|
| **មាឃបូជា** | អង្គារ 3 កុម្ភៈ | ចន្ទ 22 កុម្ភៈ | **មាឃបូជា** | សៅរ៍ 11 កុម្ភៈ | ពុធ 31 មករា |
| **ត្រស្តិសង្ក្រាន្ត (៤ថ្ងៃ)** | ចន្ទ 16 មីនា | អាទិត្យ 3 មេសា | **ត្រស្តិសង្ក្រាន្ត (៤ថ្ងៃ)** | សុក្រ 24 មីនា | អង្គារ 13 មីនា |
| **ចូលឆ្នាំថ្មី** | អង្គារ 14 មេសា 14H24 | ព្រហស្បតិ៍ 14មេសា 20H | **ចូលឆ្នាំថ្មី** | សុក្រ 14 មេសា 3H12 | សៅរ៍ 14 មេសា 9H12 |
| **ពិសាខបូជា** | សៅរ៍ 2 ឧសភា | សុក្រ 20 ឧសភា | **ពិសាខបូជា** | ពុធ 10 ឧសភា | អាទិត្យ 29 មេសា |
| **ច្រត់ព្រះនង្គ័ល** | ពុធ 6 ឧសភា | អង្គារ 24 ឧសភា | **ច្រត់ព្រះនង្គ័ល** | អាទិត្យ 14 ឧសភា | ព្រហស្បតិ៍ 3 ឧសភា |
| **ចូលវស្សា (៣ខែ)** | សុក្រ 31 កក្កដា | ពុធ 20 កក្កដា | **ចូលវស្សា (៣ខែ)** | អាទិត្យ 9 កក្កដា | សៅរ៍ 28 កក្កដា |
| **កាន់បិណ្ឌ (១៤ថ្ងៃ)** | ចន្ទ 28 កញ្ញា | សៅរ៍ 17 កញ្ញា | **កាន់បិណ្ឌ (១៤ថ្ងៃ)** | ពុធ 6 កញ្ញា | អង្គារ 25 កញ្ញា |
| **ភ្ជុំបិណ្ឌ** | ចន្ទ 12 តុលា | សៅរ៍ 1 តុលា | **ភ្ជុំបិណ្ឌ** | ពុធ 20 កញ្ញា | អង្គារ 9 តុលា |
| **ចេញវស្សា** | អង្គារ 27 តុលា | អាទិត្យ 16 តុលា | **ចេញវស្សា** | ព្រហស្បតិ៍ 5 តុលា | ពុធ 24 តុលា |
| **កឋិនទាន (២៩ថ្ងៃ)** | ពុធ 28 តុលា | ចន្ទ 17 តុលា | **កឋិនទាន (២៩ថ្ងៃ)** | សុក្រ 6 តុលា | ព្រហស្បតិ៍ 25 តុលា |

| | | | | | |
|---|---|---|---|---|---|
| **បុណ្យអុំទូក (៣ថ្ងៃ)** | អង្គារ 24 វិច្ឆិកា | អាទិត្យ 13 វិច្ឆិកា | **បុណ្យអុំទូក (៣ថ្ងៃ)** | ព្រហស្បតិ៍ 2 វិច្ឆិកា | ពុធ 21 វិច្ឆិកា |

| **ពិធីបុណ្យទ្វាទសមាស** | **2019 ឆ្នាំកុរឯកស័ក ២៥៦៣** | **2020 ឆ្នាំជូតទោស័ក ២៥៦៤** | **ពិធីបុណ្យទ្វាទសមាស** | **2021 ឆ្នាំឆ្លូវត្រីស័ក ២៥៦៥** | **2022 ឆ្នាំខាលចត្វាស័ក ២៥៦៦** |
|---|---|---|---|---|---|
| **មាឃបូជា** | អង្គារ 19 កុម្ភៈ | សៅរ៍ 8 កុម្ភៈ | **មាឃបូជា** | ព្រហស្បតិ៍ 28 មករា | ពុធ 16 កុម្ភៈ |
| **ត្រស្តិសង្ក្រាន្ត (៤ថ្ងៃ)** | ចន្ទ 1 មេសា | សុក្រ 20 មីនា | **ត្រស្តិសង្ក្រាន្ត (៤ថ្ងៃ)** | ពុធ 10 មីនា | អង្គារ 29 មីនា |
| **ចូលឆ្នាំថ្មី** | អាទិត្យ 14 មេសា 15H12 | អង្គារ 14 មេសា 20H48 | **ចូលឆ្នាំថ្មី** | ពុធ 14 មេសា 4H00 | ព្រហស្បតិ៍ 14 មេសា 10H00 |
| **ពិសាខបូជា** | សៅរ៍ 18 ឧសភា | ពុធ 6 ឧសភា | **ពិសាខបូជា** | ចន្ទ 26 មេសា | អាទិត្យ 15 ឧសភា |
| **ច្រត់ព្រះនង្គ័ល** | ពុធ 22 ឧសភា | អាទិត្យ 10 ឧសភា | **ច្រត់ព្រះនង្គ័ល** | សុក្រ 30 មេសា | ព្រហស្បតិ៍ 19 ឧសភា |
| **ចូលវស្សា (៣ខែ)** | ពុធ 17 កក្កដា | ចន្ទ 6 កក្កដា | **ចូលវស្សា (៣ខែ)** | អាទិត្យ 25 កក្កដា | ព្រហស្បតិ៍ 14 កក្កដា |
| **កាន់បិណ្ឌ (១៤ថ្ងៃ)** | សៅរ៍ 14 កញ្ញា | ព្រហស្បតិ៍ 3 កញ្ញា | **កាន់បិណ្ឌ (១៤ថ្ងៃ)** | ពុធ 22 កញ្ញា | អាទិត្យ 11 កញ្ញា |
| **ភ្ជុំបិណ្ឌ** | សៅរ៍ 28 កញ្ញា | ព្រហស្បតិ៍ 17 កញ្ញា | **ភ្ជុំបិណ្ឌ** | ពុធ 6 តុលា | អាទិត្យ 25 កញ្ញា |
| **ចេញវស្សា** | អាទិត្យ 13 តុលា | សុក្រ 2 តុលា | **ចេញវស្សា** | ព្រហស្បតិ៍ 21 តុលា | ចន្ទ 10 តុលា |
| **កឋិនទាន (២៩ថ្ងៃ)** | ចន្ទ 14 តុលា | សៅរ៍ 3 តុលា | **កឋិនទាន (២៩ថ្ងៃ)** | សុក្រ 22 តុលា | អង្គារ 11 តុលា |
| **បុណ្យអុំទូក (៣ថ្ងៃ)** | អាទិត្យ 10 វិច្ឆិកា | សុក្រ 30 វិច្ឆិកា | **បុណ្យអុំទូក (៣ថ្ងៃ)** | ព្រហស្បតិ៍ 18 វិច្ឆិកា | ចន្ទ 7 វិច្ឆិកា |

| ពិធីបុណ្យទានសមាស | 2023 ឆ្នាំថោះបញ្ចស័ក ២៥៦៧ | 2024 ឆ្នាំរោងឆស័ក ២៥៦៨ |
|---|---|---|
| មាឃបូជា | អាទិត្យ 5 កុម្ភៈ | សៅរ៍ 24 កុម្ភៈ |
| ត្រស្ដិសង្រ្កាន្ត (៤ថ្ងៃ) | សៅរ៍ 18 មីនា | សុក្រ 5 មេសា |
| ចូលឆ្នាំថ្មី | សុក្រ 14 មេសា 16H00 | អាទិត្យ 14 មេសា 22H24 |
| ពិសាខបូជា | ព្រហស្បតិ៍ 4 ឧសភា | ពុធ 22 ឧសភា |
| ច្រត់ព្រះនង្គ័ល | ចន្ទ 8 ឧសភា | អាទិត្យ 26 ឧសភា |
| ចូលវស្សា (៣ខែ) | ពុធ 2 សីហា | អាទិត្យ 21 កក្កដា |
| កាន់បិណ្ឌ (១៤ថ្ងៃ) | សៅរ៍ 30 កញ្ញា | ពុធ 18 កញ្ញា |
| ភ្ជុំបិណ្ឌ | សៅរ៍ 14 តុលា | ពុធ 2 តុលា |
| ចេញវស្សា | អាទិត្យ 29 តុលា | ព្រហស្បតិ៍ 17 តុលា |
| កឋិនទាន (២៩ថ្ងៃ) | ចន្ទ 30 តុលា | សុក្រ 18 តុលា |
| បុណ្យអុំទូក (៣ថ្ងៃ) | អាទិត្យ 26 វិច្ឆិកា | ព្រហស្បតិ៍ 14 វិច្ឆិកា |

## អ្នកនិពន្ធ

*អាន តាំងគីម បណ្ឌិតឯកទេសផ្នែកពត៌មានវិជ្ជា(កុំព្យូទ័រ) ចេញពីប្រទេសបារាំង បានចូលនិវត្តន៍បន្ទាប់ពីបានធ្វើការក្នុងធនាគារនៅប្រទេសបារាំង ។*

កើតនៅថ្ងៃសុក្រ ១កើតខែជេស្ឋ ឆ្នាំមមី ត្រូវនឹងថ្ងៃ ទី១៥ ខែឧសភា ឆ្នាំ ១៩៤២ នៅឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្តាល ។

ជាអតីតសាស្ត្រាចារ្យទុតិយភូមិផ្នែកគណិតសាស្ត្រ ចេញពីសាលាគរុកោសលជាន់ខ្ពស់ ក្រុងភ្នំពេញ បង្ហាត់ថ្នាក់ទីបញ្ចប់នៃវិទ្យាល័យ ក្រុងភ្នំពេញ ។

កាលអាយុ១២ឆ្នាំ បានបួសជាសាមណេរ (លោកនេន) នៅវត្ត មង្គលសត្ថាវ័ន ភូមិព្រែកតាគង់ ឃុំព្រែកតាសេក ស្រុកមុខកំពូល ខេត្តកណ្តាល ប្រទេសកម្ពុជា ៕

## សៀវភៅនិងឯកសារពិគ្រោះ


១- ដៃគូអ្នកកាន់ពុទ្ធសាសនា ភិក្ខុ ងិន គេន វត្តពោធិវង្ស ប្រទេសបារាំង

២- ប្រជុំ មង្គលអាពាហ៍ពិពាហ៍ខ្មែរ លោក សាគូ សាមុត ទស្សនាវដ្តី អង្គរវត្ត

៣- ប្រជុំពិធីបុណ្យ លោក ចាប ពិន បណ្ណាគារត្រៃរតន៍ ភ្នំពេញ

៤- មហាសង្ក្រាន្ត លោក រស់ វ៉ាន់ថា ព្រឹត្តិប័ត្រ សមាគម ឧបត្ថម្ភពុទ្ធសាសនាខ្មែរ វត្តពោធិវង្ស ប្រទេសបារាំង លេខ២៥ ខែមេសា ២០០៧

៤-១- វប្បធម៌ អរិយធម៌ខ្មែរ លី សុវីរ ភ្នំពេញ ឆ្នាំ២០០៤

៤-២- មហាសង្ក្រាន្ត ឱម ខែម ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ២០០១

៤-៣- សូរ្យយាត្រឡើងស័ក-ប្រតិទិន អ៊ុម ពូវ ពុទ្ធសាសនបណ្ឌិត្យភ្នំពេញ ១៩៧០

៤-៤- បញ្ជាក់សករាជ ភួង នួន ភ្នំពេញ ១៩៥៧

៤-៥- ព្រះរាជពិធីទ្វាទសមាស (ភាគ១)ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ១៩៦៩

៤-៦- Astronomie cambodgienne J.G. Faraut Phnom-Penh 1910

៤-៧- L’Astrologie dans la vie quotidienne en Thaïlande (Thèse de doctorat soutenue par Nathalie Martin) Paris 2001

៤-៨- Southeast Asian Ephemeris J.C. Eade USA 1989

៤-៩- Chroniques Royales du Cambodge – (des origines légendaires jusqu’à Paramaraja 1er) par Mak Phoeun Paris 1984

៤-១០- Samdech Phra Chao Tak Sin Maharat - Roi de Thonburi (These de doctorat soutenue par Jacqueline de Fels) Paris 1976

៤-១១- Numismatique et Change n° 317